# ដំណាំស្រូវ

## សៀវភៅណែនាំសម្រាប់ការអនុវត្តន៍ជាក់ស្តែង ក្នុងការគ្រប់គ្រងសារធាតុចិញ្ចឹម







ការគ្រប់គ្រងសារធាតុចិញ្ចឹម

កង្វះ សារធាតុចិញ្ចឹម

ការពុលសារធាតុខនិជ

វិធីសាស្ត្រ និងព័ត៌មាន

កែសម្រួលដោយ Thomas Fairhurst, Christian Witt, Roland Buresh និង Achim Dobermann

**ដំណាំស្រូវ : សៀវភៅណែនាំសម្រាប់ការអនុវត្តន៍ជាក់ស្តែង ក្នុងការគ្រប់គ្រងសារធាតុចិញ្ចឹម**

កែសម្រួលដោយ T.H. Fairhurst, C. Witt, R.J. Buresh និង A. Dobermann

creative commons

រក្សាសិទ្ធដោយ វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ
វិទ្យាស្ថានជីវជាតិរុក្ខជាតិអន្តរជាតិ និង
វិទ្យាស្ថានប៉ូតាស់អន្តរជាតិ ឆ្នាំ ២០០៧។

អ្នកប្រើប្រាស់មានសិទ្ធក្នុងការចែកចាយ បង្ហាញ និងផ្សព្វផ្សាយស្នាដៃនេះ ហើយអាចកែសម្រួលស្នាដៃនេះក្រោមល័ក្ខខ័ណ្ឌដែលបានបញ្ជាក់នៅផ្នែកខាងក្នុងនៃទំព័រខាងក្រោយរបស់ឯកសារនេះ រឺតាមរយៈគេហទំព័រ www.creativecommon.org

## កម្រិតនៃភាពទទួលខុសត្រូវតាមផ្លូវច្បាប់

ទោះបីជាក្រុមអ្នកនិពន្ធបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីធានាថា ខ្លឹមសាររបស់សៀវភៅនេះមានលក្ខណៈត្រឹមត្រូវនៅពេលបោះពុម្ពក៏ដោយ វាមិនអាចត្រឹមត្រូវគ្រប់ស្ថានភាពនោះទេ។ ខ្លឹមសារក្នុងសៀវភៅនេះឈរលើមូលដ្ឋានដែលថាសុពលភាពរបស់វាមានដូចដែលបានបញ្ជាក់ក្នុងសៀវភៅនេះ ប៉ុន្តែមិនមានការធានាឡើយ។ ទាំងអ្នកនិពន្ធ និងអ្នកបោះពុម្ព នឹងមិនរ៉ាប់រងទៅលើកាតព្វកិច្ចតាមផ្លូវច្បាប់ចំពោះការខាតបង់ប្រយោជន៍ និងការខូចខាតផ្សេងៗ ដែលបង្កឡើងដោយផ្ទាល់ ឬប្រយោលពីការអនុវត្តន៍ តាមការណែនាំក្នុងសៀវភៅនេះឡើយ។

រៀបចំរាយអត្ថបទ និងប្លង់បោះពុម្ព ដោយ Tham Sin Chee

បោះពុម្ពលើកទី ១ ឆ្នាំ ២០០២។ បោះពុម្ពសាជាថ្មី ឆ្នាំ ២០០៣, ២០០៥
បោះពុម្ពលើកទី ២ ឆ្នាំ ២០០៧
បោះពុម្ពលើកទី ១ ជាខេមរភាសា ឆ្នាំ ២០១១
ISBN-13: 978-99963-603-0-5

## អំពីអ្នកបោះពុម្ព

បេសកកម្មរបស់វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិគឺដើម្បីកាត់បន្ថយភាពក្រីក្រនិងភាពអត់ឃ្លានធ្វើអោយសុខភាពរបស់កសិករ និងអ្នកប្រើប្រាស់ដំណាំស្រូវកាន់តែមានលក្ខណៈប្រសើរឡើង និងធានានិរន្តរភាពបរិស្ថាន តាមរយៈការស្រាវជ្រាវរួមគ្នា ភាពជាដៃគូ និងការពង្រឹងប្រព័ន្ធស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មជាតិ។

បេសកកម្មរបស់វិទ្យាស្ថានជីវជាតិរុក្ខជាតិអន្តរជាតិ គឺដើម្បីជួយកំណត់មូលដ្ឋានគ្រឹះសម្រាប់ការប្រើប្រាស់ និងការគ្រប់-គ្រងសារធាតុចិញ្ចឹមរបស់រុក្ខជាតិអោយបានសមស្រប ពិសេសផ្តោតទៅលើបញ្ហាបរិស្ថាន និងសេដ្ឋកិច្ច ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់សារធាតុចិញ្ចឹមទាំងនោះ និងដើម្បីផ្តល់ជាព័ត៌មានយល់ដឹងទូទៅ ព័ត៌មានក្នុងតំបន់ និងលទ្ធផលស្រាវជ្រាវ ដើម្បីជួយដល់កសិករ និងសកម្មភាពសេដ្ឋកិច្ចនេះ តាមរយៈការដោះស្រាយបញ្ហាបរិស្ថាន និងបញ្ហាក្សេត្រសាស្ត្រ។

បេសកកម្មរបស់វិទ្យាស្ថានប៉ូតាស់អន្តរជាតិ គឺដើម្បីអភិវឌ្ឍ និងលើកកម្ពស់ការប្រើប្រាស់ជីអោយមានតុល្យភាពសម្រាប់ផលិតកម្មដែលមានទិន្នផលខ្ពស់ជាងមុន និងមានអាហារចិញ្ចឹមច្រើនជាងមុន គួបផ្សំជាមួយការធានានិរន្តរភាពរបស់ផលិតកម្ម តាមរយៈការអភិរក្សជីជាតិដីសម្រាប់មនុស្សជំនាន់ក្រោយ។

# បុព្វកថា

សន្តិសុខស្បៀងនៅអាស៊ី ពឹងផ្អែកយ៉ាងខ្លាំងទៅលើផលិតកម្មដំណាំស្រូវ តាមបែបអតិផលនៅក្នុងបរិស្ថានដ៏អំណោយផលនៃប្រព័ន្ធដាំដុះស្រោចស្រពដែលមានដំណាំស្រូវជាមូលដ្ឋាន។ ការកើនឡើងបន្ថែមទៀតនៃផលិតភាព មានសារៈសំខាន់ណាស់ដោយសារតែកំណើនប្រជាជន និងការថយចុះនៃបរិមាណទឹក និងដីដែលមាន។ការកើនឡើងនៃទិន្នផលនាពេលអនាគត ទាមទារអោយមានការកែលម្អការថែទាំដំណាំ, វិធីសាស្ត្រគ្រប់គ្រងធនធានចម្រុះ និងយុទ្ធសាស្ត្រប្រកបដោយចំណេះដឹងបន្ថែមទៀត ដើម្បីប្រើប្រាស់ទុនចំណាយទាំងអស់អោយមានប្រសិទ្ធភាព ក្នុងនោះក៏មានសារធាតុចិញ្ចឹមដែលបានមកពីដីផងដែរ។

នារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទស្សនៈនៃការគ្រប់គ្រងសារធាតុចិញ្ចឹមទៅតាមទីកន្លែងជាក់លាក់ ( Site-specific nutrient management) ត្រូវបានអភិវឌ្ឍឡើង ដើម្បីជំនួសអនុសាសន៍នៃការប្រើប្រាស់ជីដោយឯកសណ្ឋានភាព (blanket fertilizer) នៅលើផ្ទៃដីធំៗ។ វិធីសាស្ត្រថ្មីៗទាំងនេះ មានគោលបំណងធ្វើអោយការប្រើប្រាស់ជីកាន់តែមានប្រសិទ្ធភាពឡើង។ ការប្រើប្រាស់ជីអោយមានតុល្យភាព បានបង្កើនប្រាក់ចំណេញរបស់កសិករ បង្កើនទិន្នផលក្នុងមួយខ្នាតជីដែលបានប្រើប្រាស់ និងការពារបរិស្ថានតាមរយៈការទប់ស្កាត់ការប្រើប្រាស់ជីច្រើនហួសប្រមាណ។ យុទ្ធសាស្ត្រនៃការគ្រប់គ្រងសារធាតុចិញ្ចឹមទៅតាមទីកន្លែងជាក់លាក់ (SSNM) ត្រូវបានវាយតម្លៃប្រកបដោយជោគជ័យនៅលើដីស្រែកសិករជាច្រើនក្នុងទ្វីបអាស៊ី ហើយបច្ចុប្បន្ននេះ ត្រូវបានកសិករនៅអាស៊ីយកមកអនុវត្តនៅក្នុងទ្រង់ទ្រាយធំ ដើម្បីបញ្ជាក់អោយកាន់តែច្បាស់ថែមទៀត និងសម្របខ្លួនទៅនឹងយុទ្ធសាស្ត្រនេះ។

ឯកសារនេះ គឺជាការណែនាំក្នុងការអនុវត្តន៍ជាក់ស្តែង ដើម្បីអោយដឹងពីរោគសញ្ញានៃកង្វះ និងការពុលសារធាតុចិញ្ចឹម និងដើម្បីអោយដឹងពីការគ្រប់គ្រងសារធាតុចិញ្ចឹមរបស់ដំណាំស្រូវដែលដាំដុះនៅក្នុងតំបន់ត្រូពិច និងតំបន់ស៊ុបត្រូពិច។ សៀវភៅណែនាំនេះ គឺជាការបន្ថែមទៅលើឯកសារមុន IRRI/PPI-PPIC ដែលមានចំណងជើងថា ដំណាំស្រូវ : ភាពមិនប្រក្រតីបង្កដោយសារធាតុចិញ្ចឹម និងការគ្រប់គ្រងសារធាតុចិញ្ចឹម ហើយត្រូវបានរៀបចំបកប្រែ និងបោះពុម្ពជាភាសាផ្សេងៗទៀត។

យើងសង្ឃឹមថា សៀវភៅណែនាំនេះនឹងត្រូវបានផ្សព្វផ្សាយអោយបានទូលំទូលាយ និងចូលរួមចំណែកក្នុងការចែករំលែកយុទ្ធសាស្ត្រសមស្របនៃការគ្រប់គ្រងសារធាតុចិញ្ចឹម អោយបានទៅដល់កសិករដាំដុះដំណាំស្រូវនៅអាស៊ី។

Ronald P. Cantrell

*អគ្គនាយក, វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ*

Thomas Fairhurst

*នាយក, PPI-PPIC East & Southeast Asia Programs*

ម.ព.ឯ.ក AIDOC
Code: 254-001
Date:
Donated by:

# បុព្វកថាសម្រាប់ការបោះពុម្ពលើកទី ២

ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ការគ្រប់គ្រងសារជាតុចិញ្ចឹមទៅតាមទីកន្លែងជាក់លាក់ (SSNM) សម្រាប់ដំណាំស្រូវបានក្លាយទៅជាផ្នែកមួយយ៉ាងសំខាន់នៃគំនិតផ្តួចផ្តើម ក្នុងការកែលម្អការគ្រប់គ្រងសារជាតុចិញ្ចឹមក្នុងបណ្តាប្រទេសជាច្រើននៅអាស៊ី។ ការណែនាំនៃកំរិតសារជាតុចិញ្ចឹម ត្រូវបានកែតម្រូវអោយមានលក្ខណៈសមស្របទៅនឹងតម្រូវការតាមទីកន្លែងជាក់លាក់ ត្រូវបានវាយតម្លៃរួមគ្នាជាមួយកសិករដាំដុះដំណាំស្រូវ ហើយត្រូវបានលើកទឹកចិត្តតាមរយៈភាពជាដៃគូរបស់ផ្នែករដ្ឋ និងឯកជនអោយបានទូលំទូលាយ។ ការបោះពុម្ពលើកទី ១ នៃសៀវភៅ "ដំណាំស្រូវ : សៀវភៅណែនាំសម្រាប់ការអនុវត្តន៍ជាក់ស្តែងក្នុងការគ្រប់គ្រងសារជាតុចិញ្ចឹម ដែលត្រូវបានបោះពុម្ពក្នុងឆ្នាំ ២០០២ បានក្លាយជាឯកសារយោងដែលគេកំណត់យកតាមជាទូទៅ សម្រាប់ឯកសារបោះពុម្ពទាក់ទងនឹងការគ្រប់គ្រងសារជាតុចិញ្ចឹមទៅតាមទីកន្លែងជាក់លាក់។ សៀវភៅណែនាំនេះស្ថិតក្នុងតម្រូវការយ៉ាងច្រើន ដោយមានសៀវភៅចំនួន ២,០០០ ក្បាល ត្រូវបានចែកចាយ និងលក់ មកទល់នឹងពេលនេះ។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ ការគ្រប់គ្រងសារជាតុចិញ្ចឹមទៅតាមទីកន្លែងជាក់លាក់ (SSNM) ត្រូវបានកែលម្អជាបន្តបន្ទាប់តាមរយៈការស្រាវជ្រាវ និងការវាយតម្លៃ ដែលជាផ្នែកមួយនៃសមាគមស្រាវជ្រាវដំណាំស្រូវស្រោចស្រព (Irrigated Rice Research Consortium)។ ការកែលម្អទស្សនៈទាន និងការធ្វើអោយមានលក្ខណៈសាមញ្ញ ត្រូវបានគេធ្វើឡើង ពិសេសទៅលើការគ្រប់គ្រងសារជាតុអាសូត។ តារាងពណ៌ស្លឹកគំរូ ៤ ពណ៌ ត្រូវបានបង្កើតឡើង ហើយការជំរុញអោយប្រើប្រាស់តារាងពណ៌ស្លឹកថ្មីនេះត្រូវបានធ្វើបន្តដោយមានតារាងពណ៌ស្លឹកចំនួនច្រើនជាង២៥០,០០០បន្ទះត្រូវបានគេចែកចាយ រហូតដល់បំណាច់ឆ្នាំ ២០០៦។ គេហទំព័រថ្មីមួយទាក់ទងនឹងការគ្រប់គ្រងសារជាតុចិញ្ចឹមទៅតាមទីកន្លែងជាក់លាក់ (SSNM) ត្រូវបានបង្កើតឡើង (www.irri.org/irrc/ssnm) ដើម្បីផ្តល់ជាព័ត៌មានថ្មីៗ និងអនុសាសន៍ទៅតាមតំបន់ សម្រាប់តំបន់ដាំដុះដំណាំស្រូវសំខាន់ៗនៅអាស៊ី។ ដូចនេះ ការបោះពុម្ពសារជាថ្មីនៃសៀវភៅសម្រាប់ការអនុវត្តន៍ជាក់ស្តែងនេះ គឺមានសារៈសំខាន់ក្នុងការរក្សានូវព័ត៌មានថ្មីៗដែលត្រូវបានផ្តល់អោយនៅលើគេហទំព័រ SSNM និងនៅក្នុងសម្ភារៈបណ្តុះបណ្តាលនានាក្នុងស្រុក។ យើងមានភាពរីករាយណាស់ ដោយការបោះពុម្ពលើកទី ២ នេះនឹងត្រូវបានបកប្រែជាភាសាជាច្រើន ក្នុងនោះរួមមាន ភាសាបង់ហ្គាល់ ចិន ឥណ្ឌា ឥណ្ឌូនេស៊ី និងវៀតណាម។

យើងសង្ឃឹមថាសៀវភៅណែនាំនេះ នឹងបន្តផ្តល់ផលប្រយោជន៍ដល់កសិករដាំដុះដំណាំស្រូវនៅអាស៊ី ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនទិន្នផល និងប្រាក់ចំណូល តាមរយៈការគ្រប់គ្រងសារជាតុចិញ្ចឹមសមស្រប។

Robert S. Zeigler

*អគ្គនាយក, វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ*

Christian Witt

*នាយក, កម្មវិធីសម្រាប់អាស៊ីអាគ្នេយ៍ នៃវិទ្យាស្ថានសារជាតុចិញ្ចឹមរុក្ខជាតិអន្តរជាតិ*

# សេចក្តីថ្លែងអំណរគុណ


យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ :

- J.K. Ladha, David Dawe និង Mark Bell សម្រាប់ការផ្តល់ជាយោបល់ និងការណែនាំដ៏មានអត្ថប្រយោជន៍នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកយើងក្នុងការបង្រួញឯកសារផ្សេងៗ ឲទៅជាទម្រង់សៀវភៅ ដែលមានលក្ខណៈជាការអនុវត្តន៍ជាក់ស្តែង។

- អតីតបុគ្គលិករបស់វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ ពិសេស Kenneth G. Cassman និង John E. Sheehy ចំពោះការចូលរួមជាទស្សនៈទានសំខាន់ៗ ដល់ការអភិវឌ្ឍន៍ការគ្រប់គ្រងសារជាតុអាសូតរបស់រុក្ខជាតិ និងការវិភាគសក្តានុពលទិន្នផលរបស់ដំណាំស្រូវ។ សូមថ្លែងអំណរគុណដល់ Heinz-Ulrich Neue និង Dharmawansa Senadhira ចំពោះរូបភាព និងឯកសារដែលមិនទាន់មានការបោះពុម្ព ទាក់ទងនឹងការពុល និងកង្វះសារជាតុចិញ្ចឹម។

- អ្នកវិទ្យាសាស្ត្រ បុគ្គលិកផ្សព្វផ្សាយ និងកសិករទាំងអស់ ដែលបានចូលរួមក្នុងសមាគមស្រាវជ្រាវដំណាំស្រូវស្រោចស្រព សម្រាប់មតិយោបល់ និងការណែនាំដ៏មានតម្លៃជាច្រើនរបស់ពួកគេ។

- អ្នកវិទ្យាសាស្ត្រទាំងអស់ដែលបានចូលរួមចំណែកក្នុងសៀវភៅណែនាំនេះ តាមរយៈស្នាដៃបោះពុម្ពរបស់ពួកគេ។ សៀវភៅណែនាំនេះមិនបានដាក់ឯកសារយោងទេ ពីព្រោះវាត្រូវបានបង្កើតឡើងដោយផ្អែកលើស្នាដៃមុនៗ ដូចដែលបានបញ្ជាក់ក្នុងបុព្វកថា។

- Bill Hardy (IRRI) ចំពោះការជួយរបស់គាត់នៅក្នុងការរៀបចំសៀវភៅណែនាំនេះ។

- Elsevier Science សម្រាប់ការអនុញ្ញាតក្នុងការបោះពុម្ពសារជាថ្មីនូវរូបថតមួយ ដែលត្រូវដកចេញពីទស្សនាវដ្តីកិច្ចការពារដំណាំ វ៉ុលទី ១៦ (Datnoff L, ការប្រើប្រាស់ជីស៊ីលីស្យូម ដើម្បីគ្រប់គ្រងជំងឺរបស់ដំណាំស្រូវនៅផ្លរីដា), Helmut von Uexküll និង Jose Espinosa (IPNI); Pedro Sánchez (ICRAF), Mathias Becker (សាកលវិទ្យាល័យបុន, អាឡឺម៉ង់); Frank Mussgnug (ZEF, អាឡឺម៉ង់); Lawrence Datnoff (សាកលវិទ្យាល័យផ្លរីដា, សហរដ្ឋអាមេរិច); និង Takeshi Shimizu (មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្ម និងព្រៃឈើនៃខេត្តអូសាកា, ជប៉ុន) ចំពោះការផ្តល់ជាឯកសារបង្ហាញ និងរូបថត។

- ទីភ្នាក់ងារប្រទេសស្វីសសម្រាប់ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ (The Swiss Agency for Development and Cooperation), សមាគមឧស្សាហកម្មជីអន្តរជាតិ (International Fertilizer Industry Association), វិទ្យាស្ថានសារជាតុចិញ្ចឹមរុក្ខជាតិអន្តរជាតិ (IPNI), វិទ្យាស្ថានប៉ូតាស់អន្តរជាតិ (IPI) និងវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) ចំពោះការផ្តល់ជាថវិការយៈពេលយូរសម្រាប់ការអភិវឌ្ឍន៍ និងផ្សព្វផ្សាយការគ្រប់គ្រងសារជាតុចិញ្ចឹមទៅតាមទីកន្លែងជាក់លាក់ (SSNM) ទៅលើដំណាំស្រូវ ដែលរួមមានការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការបង្កើតសៀវភៅណែនាំនេះផងដែរ។

# បញ្ជីមាតិកា


បុព្វកថា........................................................................................................................... i

សេចក្តីថ្លែងអំណរគុណ ........................................................................................................iii

**១. ការគ្រប់គ្រងសារធាតុចិញ្ចឹម** ........................................................................................... ១

១.១ ទំនាក់ទំនង និងមូលហេតុនៃគម្លាតទិន្នផល ........................................................................ ១

១.២ ទស្សនៈទានមូលដ្ឋាននៃការគ្រប់គ្រង N, P និង K អោយមានតុល្យភាព.................................... ៤

១.៣ ប្រសិទ្ធភាពនៃការប្រើប្រាស់ជី ......................................................................................... ៧

១.៤ ការគ្រប់គ្រងសារជាតុចិញ្ចឹមទៅតាមទីកន្លែងជាក់លាក់ (SSNM).......................................... ៧

១.៥ ការអភិវឌ្ឍន៍កម្មវិធីជី...................................................................................................... ៨

១.៦ ការវាយតម្លៃទៅលើតម្រូវការ និងឱកាស (Needs and opportunity assessment) ..................១០

១.៧ ដែនអនុសាសន៍.............................................................................................................. ១២

១.៨ ការអភិវឌ្ឍន៍នៃអនុសាសន៍ក្នុងការប្រើប្រាស់ជី N, P និង K.................................................. ១៣

*ជំហានទី ១ ការជ្រើសរើសគោលដៅទិន្នផលដែលមានលក្ខណៈសេដ្ឋកិច្ច .................................១៦*

*ជំហានទី ២ ការប៉ាន់ប្រមាណទៅលើការផ្គត់ផ្គង់សារជាតុចិញ្ចឹមរបស់ដី..........................................១៦*

*ជំហានទី ៣ ការគណនាកម្រិតជី N និងការប្រើប្រាស់ការគ្រប់គ្រង N តាមពេលវេលាជាក់ស្តែង..............១៨*

*ជំហានទី ៤ ការគណនាកម្រិតជីផូស្វាត ...................................................................................២៧*

*ជំហានទី ៥ ការគណនាកម្រិតជីប៉ូតាស់ ...................................................................................៣០*

១.៩ ការគ្រប់គ្រងជីសរីរាង្គ ចំបើង និងជីស្រស់.................................................................................៣៤

១.១០ ការវាយតម្លៃទៅលើយុទ្ធសាស្ត្រសម្រាប់ការផ្សព្វផ្សាយឱ្យបានទូលំទូលាយ.................................៣៧

១.១១ លេខមានប្រយោជន៍..............................................................................................................៣៨

**២. កង្វះ និងការពុលសារធាតុខនិជ** ........................................................................................... ៤២

២.១ កង្វះអាសូត ........................................................................................................................... ៤២

២.២ កង្វះផូស្វ័រ............................................................................................................................៤៤

២.៣ កង្វះប៉ូតាស្យូម.........................................................................................................................៤៦

២.៤ កង្វះស័ង្កសី ............................................................................................................................៤៨

២.៥ កង្វះស្ពាន់ធ័រ ...........................................................................................................................៥០

២.៦ កង្វះស៊ីលីស្យូម ........................................................ ៥៣
២.៧ កង្វះម៉ាញេស្យូម ........................................................ ៥៥
២.៨ កង្វះកាល់ស្យូម ........................................................ ៥៧
២.៩ កង្វះដែក ........................................................ ៥៩
២.១០ កង្វះម៉ង់កាណែស ........................................................ ៦១
២.១១ កង្វះទង់ដែង ........................................................ ៦៣
២.១២ កង្វះប៊រ ........................................................ ៦៥
២.១៣ ការពុលដែក ........................................................ ៦៧
២.១៤ ការពុលស៊ុលហ្វីត ........................................................ ៧០
២.១៥ ការពុលប៊រ ........................................................ ៧៣
២.១៦ ការពុលម៉ង់កាណែស ........................................................ ៧៥
២.១៧ ការពុលម៉ាញេស្យូម ........................................................ ៧៧
២.១៨ ការពុលជាតិប្រៃ ........................................................ ៧៩

# ឧបសម្ព័ន្ធ


ការគ្រប់គ្រងដំណាំស្រូវតាមវាលស្រែ ........ A-២

ឧបករណ៍គ្រប់គ្រងសារជាតុចិញ្ចឹម : កូនស្រែដែលមិនដាក់សារជាតុចិញ្ចឹមមួយចំនួន ........ A-៤

ឧបករណ៍គ្រប់គ្រងសារជាតុចិញ្ចឹម : តារាងពណ៌ស្លឹក (LCC) ........ A-៦

ដំណាក់កាលលូតលាស់ ........ A-៨

គន្លឹះវិនិច្ឆ័យសំរាប់ធ្វើអត្តសញ្ញាណកម្មទៅលើកង្វះសារជាតុចិញ្ចឹមរបស់ដំណាំស្រូវ ........ A-១០

រោគសញ្ញានៃកង្វះអាសូត ........ A-១២

រោគសញ្ញានៃកង្វះផូស្វ័រ ........ A-១៤

រោគសញ្ញានៃកង្វះប៉ូតាស្យូម ........ A-១៦

រោគសញ្ញានៃកង្វះស័ង្កសី ........ A-១៨

រោគសញ្ញានៃកង្វះស្ពាន់ធ័រ ........ A-២០

រោគសញ្ញានៃកង្វះស៊ីលីស្យូម ........ A-២២

រោគសញ្ញានៃកង្វះម៉ាញេស្យូម ........ A-២៤

រោគសញ្ញានៃកង្វះកាល់ស្យូម ........ A-២៦

រោគសញ្ញានៃកង្វះដែក ........ A-២៨

រោគសញ្ញានៃកង្វះម៉ង់កាណែស ........ A-៣០

រោគសញ្ញានៃកង្វះទង់ដែង ........ A-៣២

គន្លឹះវិនិច្ឆ័យ សំរាប់ធ្វើអត្តសញ្ញាណកម្មទៅលើការពុលសារជាតុចិញ្ចឹមរបស់ដំណាំស្រូវ ........ A-៣៥

រោគសញ្ញានៃការពុលដែក ........ A-៣៦

រោគសញ្ញានៃការពុលស៊ុលហ្វីត ........ A-៣៨

រោគសញ្ញានៃការពុលបរ ........ A-៤០

រោគសញ្ញានៃការពុលម៉ង់កាណែស ........ A-៤២

រោគសញ្ញានៃការពុលអាលុយមីញ៉ូម ........ A-៤៤

រោគសញ្ញានៃការពុលជាតិប្រៃ ........ A-៤៦

# ១. ការគ្រប់គ្រងសារធាតុចិញ្ចឹម

*C. Witt[1], R.J. Buresh[2], S. Peng[2], V. Balasubramanian[2] និង A. Dobermann[2]*

## ១.១ ទំនាក់ទំនង និងមូលហេតុនៃគម្លាតទិន្នផល

កសិករដាំដុះដំណាំស្រូវភាគច្រើន ទទួលបានទិន្នផលតិចជាង ៦០ភាគរយ នៃសក្តានុពលទិន្នផលតាមលក្ខណៈសេណេទិច និងអាកាសធាតុនៅតាមទីកន្លែងជាក់លាក់មួយ។ គំរូដ៏សាមញ្ញមួយ ត្រូវបានគេប្រើប្រាស់ដើម្បីបកស្រាយពីកត្តានានាដែលអាចពន្យល់ពីគម្លាតទិន្នផល (រូបភាពទី ១)។

សក្តានុពលទិន្នផល រឺទិន្នផលអតិបរមា ($Y_{max}$) ត្រូវបានកំណត់ដោយកត្តាអាកាសធាតុ និងពូជស្រូវតែប៉ុននោះ ដោយមានកត្តាផ្សេងៗទៀតទាំងអស់ស្ថិតក្នុងកម្រិតប្រសើរបំផុត។ $Y_{max}$ ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ (± ១០ ភាគរយ) ដោយសារតែលក្ខណៈអាកាសធាតុ។ ចំពោះបរិស្ថានដាំដុះដំណាំស្រូវភាគច្រើននៅក្នុងតំបន់ត្រូពិចនៅអាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង, $Y_{max}$ របស់ពូជស្រូវដែលមានទិន្នផលខ្ពស់ៗនាពេលបច្ចុប្បន្ននេះ គឺប្រហែល ១០ តោនក្នុងមួយហិចតា ក្នុងរដូវដែលផ្តល់ទិន្នផលខ្ពស់ (high-yielding season) និង ៧ ទៅ ៨ តោនក្នុងមួយហិចតា ក្នុងរដូវដែលផ្តល់ទិន្នផលទាប (low-yielding season)។




រូបភាពទី ១ : ឧទាហរណ៍សម្រាប់ឥទ្ធិពលនៃការគ្រប់គ្រងសារធាតុចិញ្ចឹម និងដំណាំ ទៅលើសក្តានុពលទិន្នផល រឺទិន្នផលអតិបរមា ($Y_{max}$), គោលដៅទិន្នផល ($Y_{target}$), ទិន្នផលដែលទទួលបាន ($Y_a$) និងទិន្នផលជាក់ស្តែង (Y)។

---

1 *IPNI-IPI Southeast Asia Program, Singapore;*

2 *International Rice Research Institute, Los Baños, Philippines.*

ទិន្នផលដែលទទួលបាន (Ya) គឺជាទិន្នផលដែលកំណត់ដោយសារជាតុចិញ្ចឹម ដែលទិន្នផលនេះអាចសម្រេចបាន តាមរយៈការអនុវត្តន៍ការគ្រប់គ្រងសារជាតុចិញ្ចឹមរបស់កសិករនាពេលបច្ចុប្បន្ន ប៉ុន្តែក្នុងល័ក្ខខ័ណ្ឌដែលការគ្រប់គ្រងដំណាំទូទៅ ទឹក និងកត្តាចង្រៃ មានលក្ខណៈប្រសើរបំផុត។ Ya អតិបរមា ដែលត្រូវសម្រេចបានដោយកសិករពូកែបំផុត គឺប្រហែល ៧៥ ទៅ ៨០ ភាគរយនៃ Ymax (គឺ ៧ ទៅ ៨ តោនក្នុងមួយហិចតា ក្នុងរដូវដែលផ្តល់ទិន្នផលខ្ពស់ និង ៥ ទៅ ៦.៥ តោនក្នុងមួយហិចតា ក្នុងរដូវដែលផ្តល់ទិន្នផលទាប)។ គោលដៅទិន្នផលដែលមានលក្ខណៈសេដ្ឋកិច្ចបែបនេះ (Ytarget, រូបភាពទី ១) បានបង្កើតជាគម្លាតទិន្នផលទី ១ ដែលមានប្រហែល ២០ ទៅ ២៥ ភាគរយនៃ Ymax។ ក្នុងករណីភាគច្រើន វាមិនមានលក្ខណៈសេដ្ឋកិច្ចទេ ក្នុងការបំពេញគម្លាតទិន្នផលនេះ ពីព្រោះតែបរិមាណដ៏ច្រើននៃទុនចំណាយដែលត្រូវការ និងមានភាពប្រថុយប្រថានខ្ពស់នៃការខូចខាតដំណាំ ដោយសារតែការដួលដើម និងការវាយប្រហារពីកត្តាចង្រៃ។ ក្នុងស្ថានភាពជាក់ស្តែង, Ya មានការធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងស្រែរបស់កសិករភាគច្រើន ដោយសារតែការប្រើប្រាស់ជី N មិនគ្រប់គ្រាន់ រឺមិនមានតុល្យភាពនៃសារជាតុចិញ្ចឹម ដែលបណ្តាលអោយមានគម្លាតទិន្នផលកាន់តែធំ (គម្លាតទិន្នផលទី ២) (រូបភាពទី ១)។

ទិន្នផលជាក់ស្តែង (Y) នៅក្នុងដីស្រែរបស់កសិករ ជាញឹកញាប់ គឺទាបជាងទិន្នផលដែលអាចទទួលបាន Ya ដោយសារតែកត្តារាំងនានាក្រៅពីកត្តាអាកាសធាតុ និងការផ្គត់ផ្គង់សារជាតុចិញ្ចឹម ដែលមានដូចជា គុណភាពគ្រាប់ពូជ រុក្ខជាតិចង្រៃ កត្តាចង្រៃ ជំងឺ ការពុលសារជាតុខនិជ និងការផ្គត់ផ្គង់ទឹក (គម្លាតទិន្នផលទី ៣)។

ការស្វែងយល់អំពីគម្លាតទិន្នផល គឺមានសារៈសំខាន់ណាស់ ពីព្រោះគម្លាតទិន្នផលធ្វើអោយ

- ប្រាក់ចំណេញរបស់កសិករមានការថយចុះ
- ផលត្រឡប់មកវិញដែលទទួលបានពីការវិនិយោគនៅក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍន៍ដំណាំស្រូវ (ឧទាហរណ៍ សំណង់ រឺសំភារៈ រឺសេវាកម្មស្រោចស្រព) មានការថយចុះ
- ផលិតកម្មស្រូវមានការថយចុះ ដែលនាំអោយមានអសន្តិសុខស្បៀង និងបង្កើនតម្រូវការក្នុងការនាំចូលស្រូវអង្ករ។

ការគ្រប់គ្រងសារជាតុចិញ្ចឹមអោយបានល្អប្រសើរជាងមុន អាចជួយដល់ការកាត់បន្ថយគម្លាតទិន្នផលទី ២ ដើម្បីជាផលប្រយោជន៍ដល់កសិករ និងប្រទេសជាតិទាំងមូល។ ទោះបីជាយ៉ាងណាក៏ដោយ ផលប្រយោជន៍ធំបំផុតដែលបានមកពីការគ្រប់គ្រងសារជាតុចិញ្ចឹមអោយបានល្អប្រសើរជាងមុន ត្រូវបានគេប្រទះឃើញនៅលើដីស្រែទាំងឡាយណា ដែលមានការគ្រប់គ្រងដំណាំបានល្អ និងមានបញ្ហាកត្តាចង្រៃតិចតួច។ កសិករត្រូវតែដឹងពីកត្តានានាដែលអាចត្រូវបានផ្លាស់ប្តូរ ដើម្បីបង្កើនផលិតភាព (ការគ្រប់គ្រងដោយផ្អែកលើចំណេះដឹង) ហើយគួរតែដឹងថា ការកើនឡើងទិន្នផលខ្ពស់ គឺជាលទ្ធផលដែលទទួលបាន នៅពេលដែលកត្តារាំងជាច្រើន (ឧទាហរណ៍ បញ្ហាកត្តាចង្រៃ និងជំងឺ និងការគ្រប់គ្រងសារជាតុចិញ្ចឹមមិនសមស្រប) ត្រូវបានដោះស្រាយនៅពេលដំណាលគ្នា។

## *ការគ្រប់គ្រងដំណាំ*

ការអនុវត្តន៍ការគ្រប់គ្រងដំណាំទូទៅជាច្រើន បានជះឥទ្ធិពលទៅលើការឆ្លើយតបរបស់ដំណាំទៅនឹងការគ្រប់គ្រងសារជាតុចិញ្ចឹមដែលត្រូវបានកែលម្អ។

ពិចារណាទៅលើចំណុចដូចខាងក្រោម :

- ប្រើប្រាស់គ្រាប់ពូជដែលមានគុណភាពខ្ពស់នៃពូជសមស្របដែលផ្តល់ទិន្នផលខ្ពស់
- ស្ទូងសំណាបខ្ចី (ឧទាហរណ៍ អាយុពី ១០ ទៅ ២០ ថ្ងៃ)
- ពង្រាបដីអោយស្មើ និងរក្សាកម្រិតទឹកអោយសមស្របនៅក្នុងវាលស្រែទាំងមូល ដើម្បីធ្វើអោយមានឯកសណ្ឋានភាពដំណាំល្អ។ ការធ្វើបែបនេះ អាចកាត់បន្ថយតម្រូវការទឹកសរុប។
- ជ្រើសរើសដង់ស៊ីតេដាំដុះសមស្រប ដើម្បីធ្វើអោយការលូតលាស់ស្លឹក (បៃកស្លឹក) មានប្រសិទ្ធភាព (ឧទាហរណ៍ ២០ ទៅ ៤០ គុម្ព ក្នុងមួយម៉ែត្រក្រឡា ដោយមានសំណាប ១ ទៅ ៣ ដើម ក្នុងមួយគុម្ព ចំពោះស្រូវស្ទូង និង ៨០ ទៅ ១២០ គីឡូក្រាមគ្រាប់ពូជក្នុងមួយហិចតា ចំពោះស្រូវពង្រោះដែលព្រោះដោយគ្រាប់សើម)
- កុំអោយរុក្ខជាតិចង្រៃដុះប្រជែងយកទឹក ផ្ទៃដី ពន្លឺ និងសារជាតុចិញ្ចឹមជាមួយដើមស្រូវ។

*ការគ្រប់គ្រងសារជាតុចិញ្ចឹមអាចឈានដល់សក្តានុពលរបស់វា បានលុះត្រាណាតែមានការគ្រប់គ្រងដំនាំល្អប្រសើរតែប៉ុណ្ណោះ។*

## *កត្តាចង្រៃ និងជំងឺ*

កត្តាចង្រៃ និងជំងឺ ជះឥទ្ធិពលទៅលើការឆ្លើយតបរបស់ដំណាំទៅនឹងការគ្រប់គ្រងសារជាតុចិញ្ចឹម ដែលត្រូវបានកែលម្អ តាមរយៈការបំផ្លាញការលូតលាស់ស្លឹក (បៃកស្លឹក) ដើមស្រូវ និងគ្រាប់ស្រូវ។ កត្តាចង្រៃដែលគេជួបប្រទះញឹកញាប់នៅលើដំណាំស្រូវស្រោចស្រព គឺជំងឺរលាកស្រទបស្លឹក ជំងឺស្រពោនស្លឹកបាក់តេរី ជំងឺរលួយដើម ដង្កូវស៊ីរូងដើម ជំងឺទុងគ្រោ មមាចត្នោត កណ្តុរ និងបក្សី។

ពិចារណាទៅលើចំណុចដូចខាងក្រោម :

- ប្រើប្រាស់ពូជដែលធន់ទ្រាំទៅនឹងជំងឺ និងកត្តាចង្រៃដែលកើតឡើងជាទូទៅ
- ជៀសវាងការប្រើប្រាស់ជី N ច្រើនហួសប្រមាណ ដើម្បីទប់ស្កាត់ការបង្កើតស្លឹកខ្ចីៗជាច្រើនដែលអាចទាក់ទាញកត្តាចង្រៃ និងជំងឺ
- មុនពេលដែលប្រើប្រាស់ជី N, ត្រូវវាយតម្លៃទៅលើស្ថានភាពទូទៅរបស់ដំណាំ, ពណ៌ស្លឹក (ប្រើប្រាស់តារាងពណ៌ស្លឹក) និងឧប្បត្តិហេតុនៃជំងឺ និងកត្តាចង្រៃនានា។
- ការបំផ្លាញដោយសារជំងឺជាច្រើន (ឧទាហរណ៍ ជំងឺអុចត្នោតនៅលើស្លឹក ជំងឺរលាកស្រទបស្លឹក ជំងឺស្រពោនស្លឹកបាក់តេរី ជំងឺរលួយដើម និងជំងឺខ្មារអំបោះត្នោត) មានទំហំធំធេង នៅកន្លែងដែលជី N ច្រើនលើសលប់ និងជីប៉ូតាស្យូម (K) មិនគ្រប់គ្រាន់ ត្រូវបានគេប្រើប្រាស់ទៅលើដំណាំស្រូវដែលរងផលប៉ះពាល់ ដោយសារកង្វះ K។

- អនុវត្តវិធានការណ៍ចម្រុះការពារដំណាំ (Integrated Pest Management) ដោយសហការជាមួយកសិករដទៃទៀត។

*ការប្រើប្រាស់ជី N អោយមានប្រសិទ្ធភាព និងការផ្តល់សារជាតុចិញ្ចឹមអោយមានតុល្យភាព អាចកាត់បន្ថយគ្រោះថ្នាក់នៃការដួលដើម ការបំផ្លាញដោយកត្តាចង្រៃ និងជំងឺ។*

### *ការគ្រប់គ្រងសារធាតុចិញ្ចឹម*

គោលដៅទិន្នផលអាចនឹងត្រូវសម្រេចបាន លុះត្រាណាតែមានការផ្តល់បរិមាណសារជាតុចិញ្ចឹមគ្រប់គ្រាន់នៅពេលវេលាត្រឹមត្រូវ ដើម្បីអោយសមស្របទៅនឹងតំរូវការរបស់ដំនាំនៅរដូវដាំដុះ។

យុទ្ធសាស្ត្រគ្រប់គ្រងសារជាតុចិញ្ចឹមដែលមានប្រសិទ្ធភាព ហើយផ្តល់ផលចំណេញ គួរតែមានគោលបំណងដូចជា :

- បង្កើនអោយអស់លទ្ធភាពនូវការស្រូបយកសារជាតុចិញ្ចឹមរបស់ដំណាំពីដី និងប្រភពសារជាតុចិញ្ចឹមមានស្រាប់ក្នុងដី តាមរយៈការអនុវត្តន៍ការគ្រប់គ្រងដំណាំអោយបានល្អ។
- ប្រើប្រាស់អោយបានពេញលេញនៃសារជាតុចិញ្ចឹមដែលមាននៅក្នុងចំបើង កាកសំនល់ដំនាំ និងលាមកសត្វ។
- ប្រើប្រាស់ជីខនិជដែលត្រូវការចាំបាច់ ដើម្បីបំពេញកង្វះខាតនៃសារជាតុចិញ្ចឹមជាក់លាក់ណាមួយ។
- កាត់បន្ថយភាពប្រថុយប្រថាននៃលើការខូចខាតដំណាំ អោយមកនៅកម្រិតអប្បបរមាតាមរយៈការជ្រើសរើសគោលដៅទិន្នផលដែលមានលក្ខណៈសេដ្ឋកិច្ច និងមានលក្ខណៈជាក់ស្តែង និងតាមរយៈការអនុវត្តន៍ ការប្រើប្រាស់ជីអោយមានប្រសិទ្ធភាព និងការផ្តល់សារជាតុចិញ្ចឹមអោយមានតុល្យភាព។
- បង្កើនប្រាក់ចំណូលអោយដល់កម្រិតអតិបរមា ដោយពិចារណាទៅលើតម្លៃនៃកត្តាផលិតកម្ម ក្នុងនោះរួមមានពលកម្ម ជីសរីរាង្គ និងជីអសរីរាង្គ។

## ១.២ ទស្សនៈទានជាមូលដ្ឋាននៃការគ្រប់គ្រង N, P និង K អោយមានតុល្យភាព

### *តុល្យភាពនៃសារធាតុចិញ្ចឹម*

តុល្យភាពនៃសារជាតុចិញ្ចឹម (B) សម្រាប់ដីស្រែមួយ អាចត្រូវបានប៉ាន់ប្រមាណ ដូចខាងក្រោម (សមាសភាពទាំងអស់ត្រូវបានវាស់វែងជា គីឡូក្រាមនៃសារជាតុចិញ្ចឹមក្នុងមួយហិចតា) :

$$B = M + A + W + N_2 - C - PS - G$$

ដែល

ធាតុចូល : M ជាប្រភពសារជាតុចិញ្ចឹមដែលត្រូវបានបន្ថែម (អសរីរាង្គ និងសរីរាង្គ)។ A គឺជាកំណរបរិយាកាស (ទឹកភ្លៀង និងធូលី)។ W គឺជាទឹកស្រោចស្រព ទឹកជំនន់ និងកករ (សារជាតុចិញ្ចឹមក្នុងទម្រង់រលាយ និងក្នុងទម្រង់ជាកករ)។ $N_2$ គឺជាការចាប់យកអាសូតពីក្នុងបរិយាកាសតាមលក្ខណៈជីវៈ។

ជាតុចេញ : C គឺជាការប្រមូលយកដំណាំចេញតាមរយៈគ្រាប់ស្រូវ និងចំបើង (ស្មើនឹងបរិមាណសារធាតុចិញ្ចឹមសរុបដលែស្រូបយកដោយដំណាំដកនឹងសារធាតុចិញ្ចឹមដលែផ្តល់មកវិញក្នុងទម្រង់ជាកាកសំណល់ដំណាំ)។ PS គឺជាការបាត់បង់តាមជម្រាបឈរ និងជម្រាបដេក។ G គឺជាការបាត់បង់អាសូតសរុបក្នុងទម្រង់ជាឧស្ម័ន ដោយសារអាសូតកម្ម និងការបំភាយក្នុងទម្រង់ជាអាម៉ូញាក់ ($NH_3$)។

## ការផ្គត់ផ្គង់សារធាតុចិញ្ចឹមដែលមានស្រាប់នៅក្នុងដី និងការផ្តល់សារធាតុចិញ្ចឹមអោយមានតុល្យភាព

សារធាតុចិញ្ចឹមដែលមានស្រាប់នៅក្នុងដី គឺជាបរិមាណសារធាតុចិញ្ចឹមជាក់លាក់ណាមួយដែលបានមកពីគ្រប់ប្រភពទាំងអស់ លើកលែងតែជីគីមី (មានដូចជា ជី កាកសំណល់ដំណាំ ទឹកស្រោចស្រព) ដែលដំណាំអាចស្រូបយកបានក្នុងរដូវដាំដុះ។

សូចនករសំរាប់វាស់សារធាតុចិញ្ចឹមនៅក្នុងដីដែលងាយប្រើប្រាស់ និងអាចទុកចិត្តបាន គឺទិន្នផលគ្រាប់នៅក្នុងកូនស្រែដែលមិនដាក់សារធាតុចិញ្ចឹមមួយចំនួន (ឧទាហរណ៍ ទិន្នផលដែលកំណត់ដោយ N នៅក្នុងកូនស្រែខ័ណ្ឌដែលមិនដាក់ជីអាសូត ហើយដាក់តែជី P និង K មើលជំហានទី ២ នៅក្នុងចំណុច ១.៨)។

ការប្រើប្រាស់ជីអោយមានតុល្យភាព មានន័យថា ការផ្គត់ផ្គង់អោយដំណាំនូវបរិមាណដ៏ត្រឹមត្រូវនៃគ្រប់សារធាតុចិញ្ចឹមទាំងអស់ ដែលមិនបានផ្គត់ផ្គង់ក្នុងបរិមាណគ្រប់គ្រាន់ពីប្រភពដែលមានស្រាប់ (រូបភាពទី ២)។

នារយៈពេលប៉ុន្មានឆ្នាំដំបូងនៃបដិវត្តន៍បៃតង ការកើនឡើងនៃទិន្នផលត្រូវសម្រេចបាន ភាគច្រើនតាមរយៈការប្រើប្រាស់ជី N ដែលជាញឹកញាប់ ជី N នេះ ត្រូវទទួលបានមកពីការឧបត្ថម្ភធនរបស់រដ្ឋាភិបាល គួបផ្សំជាមួយការប្រើប្រាស់ពូជសុទ្ធ ដែលមានលក្ខណៈទំនើប (modern inbred varieties)។ ដោយឃើញទិន្នផលឆ្លើយ




រូបភាពទី ២ : ឧទាហរណ៍នៃការកម្រិតនៅក្នុងការផ្គត់ផ្គង់ N, P និង K ដែលមានស្រាប់របស់ដី ដែលត្រូវបានប៉ាន់ប្រមាណជាទិន្នផលគ្រាប់នៅក្នុងកូនស្រែខ័ណ្ឌចែកដាច់ពីគ្នា។ ចំពោះគោលដៅទិន្នផលចាស់ ដីអាចមានការកម្រិតដោយការផ្គត់ផ្គង់ N ប៉ុន្តែមិនមានការកម្រិតដោយការផ្គត់ផ្គង់ P និង K ទេ ប៉ុន្តែចំពោះគោលដៅទិន្នផលថ្មីវិញ ការផ្គត់ផ្គង់សារធាតុចិញ្ចឹមរបស់ដីអាចមានលក្ខណៈកម្រិតចំពោះសារធាតុចិញ្ចឹមទាំងបីនេះទៅតាមលំដាប់លំដោយ N > K > P។

តបទៅនឹងការប្រើប្រាស់ជីនេះ កសិករបានបង្កើនកម្រិតប្រើប្រាស់ជី N ទៅដល់កម្រិតមួយ ដែលច្រើនហួសប្រមាណ ខណៈពេលដែលពួកគេប្រើប្រាស់ជី P និង K ក្នុងបរិមាណមិនគ្រប់គ្រាន់។ ទាំងនេះបណ្តាលអោយមានការផ្គត់ផ្គង់សារធាតុចិញ្ចឹមមិនមានតុល្យភាពទៅអោយដំណាំ។ លើសពីនេះទៅទៀត សារធាតុចិញ្ចឹមដែលកាលពីមុនមិនខ្វះខាតជាញឹកញាប់បានក្លាយទៅជាខ្វះខាត ដោយសារគោលដៅទិន្នផលមានការកើនឡើងជាលំដាប់ (រូបភាពទី ២)។

ការដាំដុះដំណាំស្រូវតាមបែបអតិផលដែលផ្តល់ទិន្នផលខ្ពស់ឡើងៗ និងការដាំដុះពី ២ ទៅ ៣ ដងក្នុងឆ្នាំ បានបណ្តាលអោយមានការប្រឈមមុខទៅនឹងការធ្លាក់ចុះសារធាតុចិញ្ចឹម P និង K ដែលមានបំរុងទុកនៅក្នុងដី ដោយសារ

- សារធាតុចិញ្ចឹមដែលត្រូវបានយកចេញតាមរយៈគ្រាប់ស្រូវ មិនអាចត្រូវបានជំនួសដោយសារធាតុចិញ្ចឹមដែលមាននៅក្នុងកាកសំណល់ដំណាំ ជីសរីរាង្គ និងជីខនិជបានឡើយ
- កសិករប្រមូលយកចំបើង (ដែលមានផ្ទុកបរិមាណ K ច្រើន) ចេញពីវាលស្រែរបស់ពួកគេ ដើម្បីដាក់ក្រាលកន្លែងអោយសត្វដេក និងប្រើប្រាស់ជាថាមពល រឺបំរើបំរាស់ក្នុងវិស័យឧស្សាហកម្ម
- បរិមាណ P និង K ដែលត្រូវបានយកចេញតាមរយៈគ្រាប់ស្រូវ មានការកើនឡើង។

ចូរកត់សំគាល់ថា សមាមាត្រសមស្របបំផុតនៃជី N:P:K ដែលត្រូវផ្តល់អោយ គឺមានលក្ខណៈជាក់លាក់ទៅតាមទីកន្លែង ពីព្រោះវាអាស្រ័យទៅលើគោលដៅទិន្នផល និងសារធាតុចិញ្ចឹមដែលមានស្រាប់នៅក្នុងដី។

ប្រសិនបើការលូតលាស់របស់រុក្ខជាតិ ត្រូវបានកម្រិតដោយការផ្គត់ផ្គង់សារធាតុចិញ្ចឹមតែប៉ុននោះ តុល្យភាពនៃសារធាតុចិញ្ចឹមសមស្របបំផុត ត្រូវសម្រេចបាននៅពេលរុក្ខជាតិស្រូបយក N ប្រហែល ១៥ គីឡូក្រាម, P ប្រហែល ២.៦ គីឡូក្រាម និង K ប្រហែល ១៥ គីឡូក្រាម ក្នុងមួយតោននៃទិន្នផលគ្រាប់ (តារាងទី ១)។

តារាងទី ១ : ការស្រូបយក N, P និង K ក្នុងបរិមាណសមស្របនៅក្នុងការប្រមូលផលនៃពូជស្រូវទំនើប

| ផ្នែករបស់រុក្ខជាតិ | N | P | K |
|---|---|---|---|
| | ការស្រូបយកគិតជាគីឡូក្រាម/ទិន្នផលគ្រាប់មួយតោន | | |
| គ្រាប់ស្រូវ | ៩ | ១.៨ | ២ |
| ចំបើង | ៦ | ០.៨ | ១៣ |
| គ្រាប់ស្រូវ + ចំបើង | ១៥ | ២.៦ | ១៥ |

## ១.៣ ប្រសិទ្ធភាពនៃការប្រើប្រាស់ជី

ជីត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព នៅពេលដែល

- ភាគច្រើននៃជីដែលផ្តល់អោយ ត្រូវបានស្រូបយកដោយដំណាំ (ហៅថា ប្រសិទ្ធភាពស្តារឡើងវិញ, RE)
- មានការកើនឡើងនៃទិន្នផលខ្ពស់ក្នុង ១ គីឡូក្រាម ជីដែលបានប្រើប្រាស់ (ហៅថា ប្រសិទ្ធភាពក្សេត្រសាស្ត្រ, AE)។

$$RE\ (\%) = \frac{\text{Plant N (N fertilized – N unfertilized) in kg/ha}}{\text{Fertilizer N in kg/ha}} \times 100$$

$$AE\ (kg/kg) = \frac{\text{Grain yield (N fertilized – N unfertilized) in kg/ha}}{\text{Fertilizer N in kg/ha}}$$

ប្រសិទ្ធភាពស្តារឡើងវិញ និងប្រសទ្ធភាពក្សេត្រសាស្ត្រ ឈានដល់កម្រិតអតិបរមា នៅពេលដែល

- បរិមាណនៃសារជាតុចិញ្ចឹមដែលត្រូវបានប្រើប្រាស់ ត្រូវបានកំណត់ដោយផ្អែកលើ បរិមាណសារជាតុចិញ្ចឹមដែលមានស្រាប់នៅក្នុងដី
- ដំណាំត្រូវបានផ្តល់អោយនូវ សារជាតុចិញ្ចឹមទាំងអស់ដែលវាត្រូវការ ក្នុងបរិមាណដែលមានតុល្យភាព
- ជីត្រូវបានដាក់នៅក្នុងដីនៅជម្រៅ ដែលមានការស្រូបយកសារជាតុចិញ្ចឹមច្រើនបំផុត (ឧទាហរណ៍ ការដាក់ជីអ៊ុយរ៉េក្នុងជម្រៅជ្រៅ)
- ជី N ត្រូវបានប្រើប្រាស់ ដោយផ្អែកទៅលើការប្រែប្រួលនៃស្ថានភាព N របស់រុក្ខជាតិនៅក្នុងរដូវដាំដុះតាមរយៈការប្រើប្រាស់តារាងពណ៌ស្លឹក
- គ្រាប់ពូជដែលមានគុណភាពខ្ពស់នៃពូជដែលស៊ាំទៅនឹងទីកន្លែងដាំដុះ ត្រូវបានគេប្រើប្រាស់
- ការថែទាំដំណាំទូទៅ (ឧទាហរណ៍ ការគ្រប់គ្រងរុក្ខជាតិចង្រៃ គម្លាតគុម្ព ការគ្រប់គ្រងថ្នាលសំណាប ការគ្រប់គ្រងទឹក) ត្រូវបានអនុវត្តឡើង អោយឈានដល់កម្រិតស្តង់ដារខ្ពស់
- កត្តាចង្រៃ និងជំងឺ ត្រូវបានគ្រប់គ្រងដោយប្រើប្រាស់បច្ចេកទេសរបស់វិធានការណ៍ចម្រុះការពារដំណាំ។

## ១.៤ ការគ្រប់គ្រងសារធាតុចិញ្ចឹមទៅតាមទីកន្លែងជាក់លាក់ (SSNM)

យុទ្ធសាស្ត្រ SSNM ដែលត្រូវបានពិពណ៌នានៅទីនេះ មានគោលបំណងដើម្បីសម្រេចអោយបាននូវទិន្នផលដែលខ្ពស់ មាននិរន្តរភាព និងមានលក្ខណៈសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងសារជាតុចិញ្ចឹម និងដំណាំអោយបានសមស្រប ដោយ

- ប្រើប្រាស់គ្រប់ប្រភពទាំងអស់នៃសារជាតុចិញ្ចឹមដែលមាន អោយមានប្រសិទ្ធភាព ក្នុងនោះរួមមាន ជីសរីរាង្គកាកសំណល់រុក្ខជាតិ និងជីអសរីរាង្គ ដោយផ្អែកទៅលើលទ្ធភាពអាចរកបាន និងការចំណាយ
- អនុវត្តតាមយុទ្ធសាស្ត្រគ្រប់គ្រង N ទៅតាមតម្រូវការរបស់រុក្ខជាតិ ដោយប្រើប្រាស់តារាងពណ៌ស្លឹក (LCC)

- ប្រើប្រាស់កូនស្រែដែលមិនដាក់សារជាតុចិញ្ចឹមមួយចំនួនដែលមិនមានការប្រើប្រាស់ជី ដើម្បីកំណត់បរិមាណសារជាតុចិញ្ចឹមដែលមានស្រាប់នៅក្នុងដី (ជាពិសេស P និង K)
- ផ្តល់អោយដំណាំនូវការផ្គត់ផ្គង់សារជាតុចិញ្ចឹមដែលមានតុល្យភាព ( N, P, K និង ពពួកមីក្រូជាតុ)
- បំពេញសារជាតុចិញ្ចឹមឡើងវិញ ( ពិសេស P និង K) ដែលត្រូវបានយកចេញតាមរយៈគ្រាប់ស្រូវ និងចំបើង ដើម្បីចៀសវាងនូវការបាត់បង់សារជាតុចិញ្ចឹមដែលបំរុងទុកនៅក្នុងដី
- ជ្រើសរើសការបន្សាំនៃប្រភពជី ដែលមានការចំណាយតិចជាងគេ
- ប្រើប្រាស់គ្រាប់ពូជដែលមានគុណភាពខ្ពស់ ដង់ស៊ីតេដាំដុះសមស្រប វិធានការណ៍ចម្រុះការពារដំណាំ និងការគ្រប់គ្រងដំណាំអោយបានល្អ ដើម្បីទាញយកផលប្រយោជន៍ពេញលេញពី SSNM
- កែតម្រូវ SSNM ទៅតាមតម្រូវការក្នុងស្រុក (មានន័យថា វាយតម្លៃទៅលើទិន្នផល និងប្រាក់ចំណេញនៅក្នុងវាលស្រែរបស់កសិករ ដោយមានការចូលរួមពីកសិករ)។

## ១.៥ ការអភិវឌ្ឍកម្មវិធីជី

កម្មវិធីជីដែលពឹងផ្អែកទៅលើ SSNM អាចត្រូវបានអភិវឌ្ឍ

- ដោយកសិករសម្រាប់ដីស្រែរបស់ពួកគាត់ម្នាក់ៗ រឺ
- ដោយអ្នករៀបចំផែនការយុទ្ធនាការផ្សព្វផ្សាយសម្រាប់តំបន់ធំៗ ដែលសារជាតុចិញ្ចឹមដែលមានស្រាប់នៅក្នុងដីនៅតំបន់នោះ មានលក្ខណៈប្រហាក់ប្រហែលគ្នា ដូចដែលបាននិយាយរៀបរាប់នៅក្នុងដែនអនុសាសន៍ (ចំណុចទី ១.៧)។

ប្រើប្រាស់វិធីសាស្រ្តចូលរួម (participatory approaches) ដោយមានអ្នកស្រាវជ្រាវ បុគ្គលិកផ្សព្វផ្សាយ និងកសិករក្នុងស្រុក ចូលរួមក្នុងការអភិវឌ្ឍន៍យុទ្ធសាស្រ្តប្រើប្រាស់ជីអោយបានសមស្រប។ អនុសាសន៍ថ្មីៗ គួរតែត្រូវបានវាយតម្លៃនៅក្នុងកូនស្រែបង្ហាញ យ៉ាងហោចណាស់ក៏ត្រូវដាំដុះ ១-២ រដូវដាំដុះផងដែរ មុនពេលយកទៅអនុវត្តន៍ជាទ្រង់ទ្រាយធំ។តារាងទី២បង្ហាញពីផែនការពេលវេលាដែលត្រូវបានស្នើឡើងសម្រាប់ការអភិវឌ្ឍន៍កម្មវិធីប្រើប្រាស់ជី។

*កំណាត់សំគាល់ :*

- ត្រូវកំណត់អាទិភាពកត្តារារាំងនៅក្នុងផលិតកម្ម : ត្រូវចងចាំថាតើបច្ចេកវិទ្យាមួយណា ដែលផ្តល់នូវសក្តានុពលខ្ពស់បំផុតសម្រាប់បង្កើនផលិតភាព?
- សូមកុំបង្កើតអនុសាសន៍ច្រើនពេកក្នុងពេលតែមួយ។ ផ្តោតទៅលើបច្ចេកវិទ្យាចំនួន ២ រឺ ៣ (ឧទាហរណ៍ គុណភាពគ្រាប់ពូជដែលត្រូវបានកែលម្អ រឺកម្មវិធីប្រើប្រាស់ជី NPK ដែលមានលក្ខណៈល្អប្រសើរជាងមុន)។

✍ ប្រើប្រាស់បច្ចេកទេសដោយមានការចូលរួម (participatory techniques) ដើម្បីធ្វើការសាកល្បងអនុសាសន៍ថ្មីៗនៅលើដីស្រែមួយចំនួនតូច អោយបាន ១ រឺ ២ រដូវ ហើយបន្ទាប់មកទៀត ធ្វើការកែតម្រូវអនុសាសន៍ទាំងនោះ ដោយផ្អែកលើលទ្ធផលឆ្លើយតបដែលទទួលបានមកពីកសិករ។

✍ កង្វះសារជាតុចិញ្ចឹមដែលគេជួបប្រទះញឹកញាប់នៅលើដំណាំស្រូវ គឺកង្វះ N P និង K ប៉ុន្តែក៏មានកង្វះសារជាតុចិញ្ចឹមដទៃទៀតដែរ ដូចជា កង្វះ Zn និង កង្វះ S ពិសេសនៅក្នុងការដាំដុះដំណាំស្រូវតាមលក្ខណៈអតិផល។

**តារាងទី ២ : ផែនការពេលវេលាដែលត្រូវបានស្នើឡើង សម្រាប់ការអភិវឌ្ឍន៍ដោយមានការចូលរួម និងការធ្វើការសាកល្បងទៅលើយុទ្ធសាស្ត្រគ្រប់គ្រងសារធាតុចិញ្ចឹមដែលត្រូវបានកែលម្អ**

| រដូវកាល | សកម្មភាព |
|---|---|
| មុនរដូវកាល ១ | ជ្រើសរើសតំបន់គោលដៅមួយ។ បង្កើតកិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធនានា។<br>ធ្វើការវាយតម្លៃទៅលើតម្រូវការ និងឱកាស (NOA)។<br>ជ្រើសរើសដែនអនុសាសន៍។<br>អភិវឌ្ឍយុទ្ធសាស្ត្រប្រើប្រាស់ជី N ដែលត្រូវបានកែលម្អដំបូង ដោយផ្អែកទៅលើគោលការណ៍នៃការវាយតម្លៃទៅលើតម្រូវការ និងឱកាស (NOA) និងការគ្រប់គ្រងសារជាតុចិញ្ចឹមទៅតាមទីកន្លែងជាក់លាក់ (SSNM)។ |
| រដូវកាល ១[a] | ធ្វើការសាកល្បងទៅលើយុទ្ធសាស្ត្រប្រើប្រាស់ជី N ដែលទើបតែត្រូវបានអភិវឌ្ឍថ្មីៗនៅក្នុងស្រែរបស់កសិករដែលត្រូវបានជ្រើសរើស ដោយមានការចូលរួមពីកសិករសកម្ម។<br>ប៉ាន់ប្រមាណទៅលើការផ្គត់ផ្គង់ N, P និង K ដែលមានស្រាប់។<br>ពិនិត្យទៅលើសុពលភាពនៃដែនអនុសាសន៍ដែលត្រូវបានជ្រើសរើស។ |
| មុនរដូវកាល ២ | អភិវឌ្ឍអនុសាសន៍ប្រើប្រាស់ជី នៅក្នុងកិច្ចសហប្រតិបត្តិការជាមួយកសិករ និងអ្នកឯកទេសខាងផ្សព្វផ្សាយ។ |
| រដូវកាល ២ និង ៣ | ធ្វើការសាកល្បង និងកែលម្អអនុសាសន៍ថ្មីៗ នៅក្នុងកូនស្រែបង្ហាញដែលស្ថិតក្នុងស្រែរបស់កសិករ។<br>បញ្ជាក់ពីការប៉ាន់ប្រមាណទៅលើការផ្គត់ផ្គង់ N, P និង K ដែលមានស្រាប់ នៅក្នុងរដូវកាល ២ និង/រឺ ៣។ |
| រដូវកាល ៤ និង ៥ | ផ្សព្វផ្សាយអនុសាសន៍ក្នុងការប្រើប្រាស់ជីអោយបានទូលំទូលាយនៅក្នុងដែនអនុសាសន៍ដែលត្រូវបានជ្រើសរើស។<br>ត្រួតពិនិត្យ និងវាយតម្លៃ! |

[a] *រដូវដែលផ្តល់ទិន្នផលខ្ពស់ដោយមានល័ក្ខខ័ណ្ឌអាកាសធាតុអំណោយផល និងមានសម្ពាធតិចតួចពីកត្តាចង្រៃ។*

## ១.៦ ការវាយតម្លៃទៅលើតម្រូវការ និងឱកាស

ដោយផ្អែកលើកម្រិតផលិតកម្ម និងតម្លៃជីនាពេលបច្ចុប្បន្ន ការកើនឡើងនៃប្រាក់ចំណេញភាគច្រើននៅក្នុងការដាំដុះដំណាំស្រូវនៅអាស៊ី អាចត្រូវសម្រេចបានតាមរយៈការបង្កើនទិន្នផល ហើយមួយចំណែកទៀតបានមកពីការកាត់បន្ថយការចំណាយ។ ការចំណាយទៅលើជី អាចត្រូវបានកាត់បន្ថយអោយមកនៅកម្រិតទាបបំផុត តាមរយៈការជ្រើសរើសបន្សំនៃប្រភពជីក្នុងស្រុកដែលអាចរកទិញបាន ដើម្បីអោយមានការចំណាយតិចបំផុត និងតាមរយៈការប្រើប្រាស់ជីអោយមានប្រសិទ្ធភាព និងមានតុល្យភាព (ឧទាហរណ៍ បង្កើនចំណាយលើសារធាតុចិញ្ចឹមដែលមានតិចតួច និងបន្ថយចំនាយលើសារធាតុចិញ្ចឹមដែលមានច្រើនស្រាប់)។

ការស្វែងយល់ពីកត្តារាំងផ្អែកសេដ្ឋកិច្ចសង្គមនិងជីវរូបសាស្ត្រនៅក្នុងផលិតកម្មរបស់កសិករមានអត្ថប្រយោជន៍ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍យុទ្ធសាស្ត្ររបស់យុទ្ធនាការផ្សព្វផ្សាយ ហើយវាអាចត្រូវសម្រេចបានយ៉ាងល្អបំផុត តាមរយៈការវាយតម្លៃទៅលើតម្រូវការ និងឱកាស (needs and opportunity assessment) :

- វាយតម្លៃទៅការអនុវត្តការគ្រប់គ្រងដំណាំ សារធាតុចិញ្ចឹម និងកត្តាចង្រៃរបស់កសិករនាពេលបច្ចុប្បន្ន ដើម្បីកំនត់កត្តារាំងនានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រង
- វាយតម្លៃភាពយល់ដឹងរបស់កសិករអំពីកត្តារាំងរបស់ផលិតភាព ដែលកត្តារាំងទាំងនេះ ត្រូវបានកំនត់ក្នុងអំឡុងពេលនៃការស្ទង់មតិ
- វាយតម្លៃថាតើមានឱកាសគ្រប់គ្រាន់ដែររឺទេក្នុងការបង្កើនផលិតភាពដោយគិតពិចារណាទៅលើចំណាប់អារម្មណ៍របស់កសិករ (និងតម្លៃ-ឱកាសនៃពេលវេលារបស់កសិករ) និងសមត្ថភាពរបស់អ្នកពាក់ព័ន្ធទាំងអស់ (កសិករ អង្គភាពក្រៅរដ្ឋាភិបាល បុគ្គលិកផ្សព្វផ្សាយ ភ្នាក់ងាររដ្ឋាភិបាលក្នុងស្រុក ។ល។) ក្នុងការអនុវត្តកម្មវិធីមួយ។

### *ការជ្រើសរើសតំបន់គោលដៅសមស្រប*

ជ្រើសរើសតំបន់គោលដៅដោយផ្អែកទៅលើលទ្ធផលនៃការវាយតម្លៃទៅលើតម្រូវការ និងឱកាស (NOA) ទស្សនកិច្ចសិក្សាដំបូងតាមវាលស្រែ ការពិភាក្សាជាមួយអ្នកពាក់ព័ន្ធ និងព្រំប្រទល់រដ្ឋបាល។ តំបន់គោលដៅដែលសមស្របសម្រាប់ការបញ្ចូលយុទ្ធសាស្ត្រគ្រប់គ្រងសារធាតុចិញ្ចឹម ដែលមានលក្ខណៈល្អប្រសើរជាងមុនគួរតែមានលក្ខណៈមួយ រឺច្រើននៃលក្ខណៈដូចខាងក្រោម :

- ការប្រើប្រាស់ជីមិនគ្រប់គ្រាន់ រឺមិនមានតុល្យភាព ដែលធ្វើអោយទិន្នផលដែលទទួលបានមានកម្រិតទាប ទោះបីជាមានសក្តានុពលទិន្នផលខ្ពស់ក៏ដោយ (ចំណុច ១.១)។ ស្វែងយល់អំពីការប្រើប្រាស់ជីក្នុងស្រុកពីកសិករ អ្នកផ្គត់ផ្គង់ជី និងបុគ្គលិកផ្សព្វផ្សាយ។
- ការលេចឡើងនូវរោគសញ្ញាកង្វះសារធាតុចិញ្ចឹម (ចំណុច ២)
- ការលេចឡើងនូវបញ្ហាកត្តាចង្រៃដែលទាក់ទងនឹងអតុល្យភាពនៃសារធាតុចិញ្ចឹម រឺការប្រើប្រាស់ជី N ច្រើនហួសប្រមាណ (ឧទាហរណ៍ ជំងឺរលាកស្រទបស្លឹក...)
- ការប្រើប្រាស់ជី N គ្មានប្រសិទ្ធភាព ដោយសារតែការប្រើប្រាស់ជីអាសូតសរុបមានកម្រិតខ្ពស់ រឺការបែងចែកការប្រើប្រាស់ជី មិនបានគ្រប់គ្រាន់ និងនៅពេលវេលាមិនសមស្រប ឧទាហរណ៍ ប្រសិនបើកសិករ

- ប្រើប្រាស់កម្រិតជី N > ១៧៥ គីឡូក្រាម ក្នុងមួយហិចតា
- ប្រើប្រាស់ជី N ក្នុងបរិមាណដ៏ច្រើន ក្នុងដំណាក់កាលលូតលាស់ដំបូងរបស់ដំណាំ (> ៥០ គីឡូក្រាមអាសូតក្នុងមួយហិចតា ក្នុងអំឡុងពេល ១០ ថ្ងៃដំបូងបន្ទាប់ពីស្ទូង រឺបន្ទាប់ពីព្រោះគ្រាប់ រឺ > ៧៥ គីឡូក្រាមអាសូតក្នុងមួយហិចតាក្នុងអំឡុងពេល ២០ ថ្ងៃដំបូង បន្ទាប់ពីស្ទូង រឺបន្ទាប់ពីព្រោះគ្រាប់)
- បាចជីបំប៉ន > ៥០ គីឡូក្រាមអាសូតក្នុងមួយហិចតាពេលបាចជីម្តងៗ
- ត្រូវការប្រើប្រាស់ជី > ៥៥ គីឡូក្រាមអាសូតក្នុងមួយហិចតា (ជីអ៊ុយរ៉េ ១២០ គីឡូក្រាមក្នុងមួយហិចតា) សម្រាប់ការកើនឡើងទិន្នផលមួយតោនៗ នៅក្នុងកូនស្រែ 0 N (កូនស្រែដែលមិនទទួលបានជីអាសូត)
- ជួបបញ្ហាដួលដើម

- កស្តុតាងនៃការប្រើប្រាស់យ៉ាងខ្លាំងទៅលើ P និង K ដែលមានស្រាប់នៅក្នុងដី ឧទាហរណ៍ ប្រសិនបើកសិករដាំដុះដំណាំពីរ រឺច្រើនដងក្នុងមួយឆ្នាំ ក្នុងកម្រិតទិន្នផលពីមធ្យម ទៅដល់ ខ្ពស់ ហើយក្នុងកំឡុង ៥ ឆ្នាំមុន
  - បានប្រើប្រាស់ផូស្វាតតិចជាង ២០ គីឡូក្រាមក្នុងមួយហិចតា នៅក្នុងការដាំដុះមួយដង រឺ
  - បានប្រើប្រាស់ផូស្វាតតិចជាង ១០ គីឡូក្រាមក្នុងមួយហិចតា នៅក្នុងការដាំដុះមួយដង ហើយច្រូតយកចំបើងភាគច្រើនចេញពីវាលស្រែ។

## ថ្លៃ លទ្ធភាពអាចរកបាន និងគុណភាពនៃប្រភពសារធាតុចិញ្ចឹម

ការអនុវត្តន៍ការប្រើប្រាស់ជីដែលមានលក្ខណៈល្អប្រសើរជាងមុន នឹងត្រូវបានទទួលយកដោយកសិករលុះត្រាណាតែ

- ការអនុវត្តន៍នោះ បានបង្កើនផលចំណេញសេដ្ឋកិច្ចច្រើនជាងមុនដល់កសិករ ហើយ
- កសិករអាចរកបានជីខនិជ ដែលមានគុណភាពខ្ពស់ក្នុងបរិមាណគ្រប់គ្រាន់នៅក្នុងតំបន់របស់ពួកគាត់។

ការពិនិត្យប្រៀបធៀបទៅលើថ្លៃជី និងគុណភាពជី គួរតែត្រូវបានបញ្ចូលជាផ្នែកមួយនៃការវាយតម្លៃទៅលើតម្រូវការ និងឱកាស (NOA)។

## ការវិភាគទៅលើចំណេញដុល

មុនពេលដែលធ្វើការសាកល្បងអនុសាសន៍ថ្មីៗនៅក្នុងវាលស្រែ ត្រូវបញ្ចប់ការវិភាគទៅលើចំណេញដុល រឺការវិភាគទៅលើប្រាក់ចំណេញ ដើម្បីកំណត់

- តម្លៃនៃការចំណាយទៅលើទុនចំណាយទាំងអស់ ដែលត្រូវបានបញ្ជាក់ជាទិន្នផលគ្រាប់ (មានន័យថា ទិន្នផលត្រង់ចំណុចស្រង់ដើម)
- ការចំណាយបន្ថែមទៀត ទៅលើទុនចំណាយដែលចាំបាច់សម្រាប់ការអនុវត្តន៍ថ្មីនោះ
- ការចំណាយបន្ថែមទៀត (ឧទាហរណ៍ ការចំណាយទៅលើកំលាំងពលកម្ម) ដែលចាំបាច់នៅក្នុងការអនុវត្តន៍ការប្រើប្រាស់ជីថ្មី និង
- ការកើនឡើងនៃប្រាក់ចំណេញសុទ្ធ (ក្រោយពេលទូទាត់) ប្រៀបធៀបជាមួយនឹងការអនុវត្តន៍ពីមុន។

*ការយល់ព្រមក្នុងការផ្លាស់ប្តូរ*

កសិករ គឺជាដៃគូដ៏សំខាន់បំផុតនៅក្នុងការអភិវឌ្ឍន៍អនុសាសន៍ក្នុងការប្រើប្រាស់ជី ដែលត្រូវបានកែលម្អ ហើយគួរតែត្រូវបានពិគ្រោះយោបល់ជាមួយចាប់តាំងពីពេលដំបូង តាមរយៈការវិភាគទៅលើតម្រូវការ និងឱកាស ( NOA ) និងវិធីសាស្ត្រដែលមានការចូលរួម (participatory approaches) ក្នុងអំឡុងពេលធ្វើការបញ្ជាក់អះអាងយុទ្ធសាស្ត្រថ្មីៗ។

អ្នកអង្កេតតាមដាន ត្រូវតែបញ្ជាក់ថា ជី កំលាំងពលកម្ម និងដើមទុន គឺអាចរកបានក្នុងបរិមាណគ្រប់គ្រាន់ដើម្បីទទួលយកនូវបច្ចេកវិទ្យាថ្មីនោះ។ ពិនិត្យតាមដានទៅលើប្រភពនៃឥណទាន និងអត្រាការប្រាក់ដែលកសិករអាចខ្ចីលុយបានសម្រាប់ទិញសំភារៈ វត្ថុចាំបាច់សម្រាប់ផលិតកម្មរបស់ពួកគាត់។

កសិករទំនងជាទទួលយកកម្មវិធីប្រើប្រាស់ជីថ្មី ប្រសិនបើយុទ្ធសាស្ត្រនោះ

- ធ្វើអោយទិន្នផលកើនឡើងយ៉ាងហោចណាស់ ០.៥តោន ក្នុងមួយហិចតា ("ការមើលឃើញ គឺជាការជឿជាក់")
- ធ្វើអោយប្រាក់ចំណេញនៃកសិដ្ឋានរបស់ពួកគាត់ មានការកើនឡើងខ្លាំង និង
- អាចរួមបញ្ចូលគ្នាជាមួយការអនុវត្តន៍នៃការគ្រប់គ្រងជាទូទៅរបស់កសិករនាពេលបច្ចុប្បន្ន (ដែលរួមមានតម្រូវការកំលាំងពលកម្ម)។

## ១.៧ ដែនអនុសាសន៍

អភិវឌ្ឍអនុសាសន៍ក្នុងការប្រើប្រាស់ជីនៅក្នុងតំបន់គោលដៅ ដោយពឹងផ្អែកទៅលើដែនអនុសាសន៍ ដែលត្រូវបានកំណត់។ ដែនអនុសាសន៍ អាចជាតំបន់ ដែលយ៉ាងតិចបំផុតមានលក្ខណៈជីវរូបសាស្ត្រ និងសេដ្ឋកិច្ចសង្គម ដែលកំណត់ទៅលើលក្ខណៈឯកសណ្ឋានភាពនៃសក្តានុពលទិន្នផល ការផ្គត់ផ្គង់សារធាតុចិញ្ចឹមដែលមានស្រាប់ និងការឆ្លើយតបតាមការរំពឹងទុកទៅនឹងការប្រើប្រាស់ជីនៅក្នុងដែនអនុសាសន៍នោះ។ ដែនអនុសាសន៍មួយ អាចមានលក្ខណៈជាតំបន់មួយដែលមាន

- ព្រំប្រទល់នៃទីជម្រាលមួយ
- ប្រតិទិនដាំដុះ និងប្រព័ន្ធដាំដុះទូទៅ
- លទ្ធភាពស្រដៀងគ្នាក្នុងការទទួលបានទឹកស្រោចស្រព
- ស្ថានភាពជីជាតិដីស្រដៀងគ្នា (ផ្អែកទៅលើព័ត៌មានដែលមានស្រាប់ទាក់ទងនឹងជីជាតិដី ដែលរួមមានផែនទីដែលនិយាយអំពីវាយនភាពដី និងលក្ខណៈរបស់ដីដទៃទៀត, ឋានលេខា, ចំណេះដឹងក្នុងស្រុករបស់កសិករ និងបុគ្គលិកផ្សព្វផ្សាយ) និង
- ព្រំប្រទល់ដែលអាចរួមបញ្ចូលតំបន់រដ្ឋបាលច្រើន។

ស្ថានភាពជីជាតិដីនៅក្នុងដែនអនុសាសន៍មួយ អាចត្រូវបានបញ្ជាក់ដោយការប៉ាន់ប្រមាណសារធាតុចិញ្ចឹមដែលមានស្រាប់របស់ដី ដោយប្រើប្រាស់កូនស្រែដែលមិនដាក់សារធាតុចិញ្ចឹមមួយចំនួន (សូមមើលចំណុច ១.៨)។ ទំហំនៃដែនអនុសាសន៍មួយ អាចមានភាពខុសប្លែកគ្នាយ៉ាងខ្លាំង ដោយអាស្រ័យទៅលើភាពខុសគ្នានៃកត្តាកំណត់ដែលបាននិយាយរៀបរាប់ខាងលើ។

*អនុសាសន៍*

បន្ទាប់មកទៀត អនុសាសន៍នានា ត្រូវបានអភិវឌ្ឍឡើងរួមគ្នាជាមួយកសិករ ដោយប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួម (participatory approaches)។ អនុសាសន៍ដាច់ពីគ្នា អាចត្រូវបានគេផ្តល់អោយសម្រាប់ភាពខុសប្លែកគ្នានៃ

- គោលដៅទិន្នផល ( រឹកម្រិតនៃទុនចំណាយ )
- វិធីសាស្ត្រក្នុងការដាំដុះដំណាំ
- ពូជ និង
- ការអនុវត្តន៍ក្នុងការគ្រប់គ្រងកាកសំណល់

ដើម្បីឆ្លើយតបទៅនឹងការអនុវត្តន៍ តម្រូវការ និងចំណាប់អារម្មណ៍នាពេលបច្ចុប្បន្នរបស់កសិករនៅក្នុងដែនអនុសាសន៍នោះ។

## ១.៨ ការអភិវឌ្ឍន៍នៃអនុសាសន៍ក្នុងការប្រើប្រាស់ជី N P និង K

ចំណុចនេះ រៀបរាប់អំពីរបៀប គណនាកម្រិតប្រើប្រាស់ជី N P និង K អោយមានតុល្យភាព ដើម្បីសម្រេចបាននូវគោលដៅទិន្នផល និងផ្តល់ជាការណែនាំសម្រាប់ពេលវេលា និងការបែងចែកការប្រើប្រាស់ជី N និង K (តារាងទី៣)។វិធីសាស្ត្រនេះអាចត្រូវបានប្រើប្រាស់ដោយអ្នករៀបចំផែនការយុទ្ធនាការផ្សព្វផ្សាយដើម្បីបង្កើតអនុសាសន៍សម្រាប់ដែនដែលមានទំហំធំជាងមុន (ចំណុចទី ១.៧) រឺត្រូវបានប្រើប្រាស់ដោយកសិករ ដើម្បីបង្កើតអនុសាសន៍ក្នុងការប្រើប្រាស់ជីសម្រាប់ដីស្រែមួយ។

ប្រសិនបើកម្មវិធីប្រើប្រាស់ជីពេញលេញមួយ ត្រូវបានគេបង្កើតឡើងសម្រាប់ដែន អនុសាសន៍មួយ, ការគណនាជីមានជំហានដូចខាងក្រោម :

*ជំហានទី ១* ការជ្រើសរើសគោលដៅទិន្នផលដែលមានលក្ខណៈសេដ្ឋកិច្ច

*ជំហានទី ២* ការប៉ាន់ប្រមាណទៅលើការផ្គត់ផ្គង់សារជាតុចិញ្ចឹមរបស់ដី

*ជំហានទី ៣* ការគណនាកម្រិតជី N និងបំរើបំរាស់នៃការគ្រប់គ្រង N ដោយផ្អែកលើតម្រូវការរបស់រុក្ខជាតិ

*ជំហានទី ៤* ការគណនាកម្រិតជីផូស្វាត ($P_2O_5$)

*ជំហានទី ៥* ការគណនាកម្រិតជីប៉ូតាស់ ($K_2O$)។

វិធីសាស្ត្រនានាក្នុងការគណនាកម្រិតជីដែលមាននៅក្នុងជំពូកនេះ គឺផ្អែកទៅលើការសន្មតទូទៅដូចខាងក្រោមដែល

- ពូជស្រូវដែលផ្តល់ទិន្នផលខ្ពស់ដែលមានសន្ទស្សន៍នៃការប្រមូលផលប្រហែល ០.៥០ ត្រូវបានគេប្រើប្រាស់។
- គោលដៅទិន្នផលដែលមានលក្ខណៈសេដ្ឋកិច្ច ដែលមិនលើសពី ៧៥-៨០ ភាគរយ នៃសក្តានុពលទិន្នផលត្រូវបានគេជ្រើសរើស។
- ការប្រើប្រាស់ជី N, P និង K អោយមានតុល្យភាព ត្រូវបានគេអនុវត្តតាម។
- ជី N ត្រូវបានផ្គត់ផ្គង់ក្នុងចំនួនដ៏សមស្របបំផុតនៃការបែងចែកការប្រើប្រាស់ជី ដែលត្រឹមត្រូវទៅតាមពេលវេលាដោយប្រើប្រាស់តារាងពណ៌ស្លឹក (LCC)។
- ការអនុវត្តការគ្រប់គ្រងដំណាំអោយបានល្អ ត្រូវបានគេអនុវត្តតាម។
- កត្តារាំងរទៃទៀតដូចជាការផ្គត់ផ្គង់ទឹកការរាតត្បាតរបស់រុក្ខជាតិចង្រៃនិងកត្តាចង្រៃនិងជំងឺមិនបានប៉ះពាល់ធ្ងន់ធ្ងរទៅលើការលូតលាស់របស់ដំណាំទេ។

តារាងទី ៣ : ម៉ាទ្រីសសម្រាប់ការបង្កើតអនុសាសន៍ក្នុងការប្រើប្រាស់ជី N P និង K

| | ខ្នាត | រដូវប្រាំង | រដូវវស្សា |
|---|---|---|---|
| **ជំហានទី ១ : ជ្រើសរើសគោលដៅទិន្នផលដែលមានលក្ខណៈសេដ្ឋកិច្ច** | | | |
| សក្តានុពលទិន្នផល | តោន/ហិចតា | | |
| ទិន្នផលជាក់ស្តែងនៅក្នុងស្រែរបស់កសិករ (មធ្យម) | តោន/ហិចតា | | |
| គោលដៅទិន្នផល | តោន/ហិចតា | | |
| **ជំហានទី ២ : ប៉ាន់ប្រមាណទៅលើការផ្គត់ផ្គង់សារធាតុចិញ្ចឹមរបស់ដី តាមរយៈទិន្នផលនៅក្នុងកូនស្រែខ័ណ្ឌចែកដាច់ពីគ្នា** | | | |
| ទិន្នផលកម្រិតដោយ N (ទិន្នផលនៅក្នុងកូនស្រែ 0 N) | តោន/ហិចតា | | |
| ទិន្នផលកម្រិតដោយ P (ទិន្នផលនៅក្នុងកូនស្រែ 0 P) | តោន/ហិចតា | | |
| ទិន្នផលកម្រិតដោយ K (ទិន្នផលនៅក្នុងកូនស្រែ 0 K) | តោន/ហិចតា | | |
| **ជំហានទី ៣ : គណនាកម្រិតប្រើប្រាស់ជី N និងការប្រើប្រាស់ការគ្រប់គ្រង N ដោយផ្អែកលើតម្រូវការរបស់រុក្ខជាតិ** | | | |
| ការកើនឡើងនៃទិន្នផលដែលត្រូវការ (គោលដៅទិន្នផលទាបជាងទិន្នផលនៅក្នុងកូនស្រែ 0 N) | តោន/ហិចតា | | |
| ប៉ាន់ប្រមាណទៅលើបរិមាណជី N សរុបដែលត្រូវការ | គីឡូក្រាម/ហិចតា | | |
| ការប្រើប្រាស់ជី N ដំបូង (ក្នុងរយៈពេល ១៤ ថ្ងៃ បន្ទាប់ពីស្ទូង រឺ ២១ ថ្ងៃ បន្ទាប់ពីព្រោះគ្រាប់) | គីឡូក្រាម/ហិចតា | | |

| | ខ្នាត | រដូវប្រាំង | រដូវវស្សា |
|---|---|---|---|
| *ជម្រើសទី ១ : វិធីសាស្ត្រតាមពេលវេលាជាក់ស្តែង* | | | |
| កម្រិត N ពេញក្នុងរដូវដាំដុះ (..... ទៅ .....បន្ទាប់ពីស្ទូង / បន្ទាប់ពីព្រោះគ្រាប់) | គីឡូក្រាម/ហិចតា | | |
| តម្លៃគ្រោះថ្នាក់នៅលើតារាងពណ៌ស្លឹក | លេខរបស់បន្ទះ | | |
| ចន្លោះពេលនៃការធ្វើអំណាន | ថ្ងៃ | | |
| *ជម្រើសទី ២ : វិធីសាស្ត្រតាមពេលវេលាថេរ* | | | |
| ការបាចជីបំប៉នលើកទី ១ នៅដំណាក់កាលបែកគុម្ពសកម្ម | គីឡូក្រាម/ហិចតា | | |
| ការបាចជីបំប៉នលើកទី ២ នៅដំណាក់កាលកំណកំណើតកួរ | គីឡូក្រាម/ហិចតា | | |
| ការបាចជីបំប៉នបន្ថែមទៀត (ទៅតាមការសម្រេចចិត្ត) នៅដើមដំណាក់កាលចេញកួរដំបូង | គីឡូក្រាម/ហិចតា | | |
| តម្លៃគ្រោះថ្នាក់នៅលើតារាងពណ៌ស្លឹក | លេខរបស់បន្ទះ | | |
| **ជំហានទី ៤ : គណនាកម្រិតជី $P_2O_5$** | | | |
| កម្រិតជី $P_2O_5$ សម្រាប់ការថែរក្សា | គីឡូក្រាម/ហិចតា | | |
| **ជំហានទី ៥ : គណនាកម្រិតជី $K_2O$** | | | |
| បរិមាណចំបើងដែលផ្តល់ត្រឡប់ទៅវិញ មុនរដូវដាំដុះ | ទាប/មធ្យម/ខ្ពស់ | | |
| កម្រិតជី $K_2O$ សម្រាប់ការថែរក្សា | គីឡូក្រាម/ហិចតា | | |
| ការប្រើប្រាស់លើកទី ១ នៅថ្ងៃបន្ទាប់ពីស្ទូង / បន្ទាប់ពីព្រោះគ្រាប់ (ភាគរយ) | គីឡូក្រាម/ហិចតា | | |
| ការប្រើប្រាស់លើកទី ២ នៅថ្ងៃបន្ទាប់ពីស្ទូង / បន្ទាប់ពីព្រោះគ្រាប់ (ភាគរយ) | គីឡូក្រាម/ហិចតា | | |

## ជំហានទី ១ ការជ្រើសរើសគោលដៅទិន្នផលដែលមានលក្ខណៈសេដ្ឋកិច្ច

- ជ្រើសរើសគោលដៅទិន្នផល ដោយផ្អែកទៅលើទិន្នផលមធ្យមនៃការដាំដុះ ៣ - ៥ ដងចុងក្រោយ (រដូវដូចគ្នា) ដែលអាចទទួលបានតាមរយៈការអនុវត្តន៍ការគ្រប់គ្រងដំណាំអោយបានល្អនាពេលបច្ចុប្បន្នរបស់កសិករ នៅពេលដែលកត្តារាំងដែលទាក់ទងនឹងសារធាតុចិញ្ចឹម ត្រូវបានគេជំនះបាន (សូមមើលកូនស្រែ NPK រូបភាពទី ៣)។

- គោលដៅទិន្នផល ឆ្លុះបញ្ចាំងពីបរិមាណសារធាតុចិញ្ចឹមសរុប ដែលត្រូវតែស្រូបយកដោយដំណាំ។ វាមានលក្ខណៈជាក់លាក់ទៅតាមទីកន្លែង និងតាមរដូវកាល ដោយអាស្រ័យទៅលើអាកាសធាតុ ពូជ និងការគ្រប់គ្រងដំណាំ។

- ជ្រើសរើសគោលដៅទិន្នផលដែលមិនលើសពី ៧៥- ៨០ ភាគរយ នៃទិន្នផលសក្តានុពល ($Y_{max}$) ដែលបានត្រូវកំណត់ជាមួយនឹងគំរូនៃការលូតលាស់របស់ដំណាំ ដោយនិម្មិតកម្មដំណាំ (crop simulation models)។ គោលដៅទិន្នផលដែលឋិតនៅកៀកបំផុតនឹងទិន្នផលសក្តានុពល អាចត្រូវការបរិមាណជីច្រើនជាងមុន និងបង្កើនភាពប្រថុយប្រថាននៃបរាជ័យក្នុងការដាំដុះដំណាំ និងការខាតបង់ប្រាក់ចំណេញ។

- ជ្រើសរើសគោលដៅទិន្នផលខ្ពស់ជាងមុន នៅក្នុងរដូវដែលផ្តល់ទិន្នផលខ្ពស់ (ល័ក្ខខ័ណ្ឌអាកាសធាតុអំណោយផល) និងជ្រើសរើសគោលដៅទិន្នផលកម្រិតមធ្យមក្នុងរដូវដែលផ្តល់ទិន្នផលទាប (ល័ក្ខខ័ណ្ឌអាកាសធាតុមិនសូវអំណោយផល ហើយភាពប្រថុយនៃបរាជ័យក្នុងការដាំដុះដំណាំ មានកម្រិតខ្ពស់ជាងមុន ដោយសារតែការដួលដើម រីកត្តាចង្រៃ និងជំងឺ)។

## ជំហានទី ២ ការប៉ាន់ប្រមាណ សារធាតុចិញ្ចឹមដែលមានស្រាប់នៅក្នុងដី

ប្រើប្រាស់ទិន្នផលគ្រាប់ នៅក្នុងកូនស្រែដែលមិនដាក់សារធាតុចិញ្ចឹមមួយចំនួន(ស្ថិតក្រោមល័ក្ខខ័ណ្ឌអាកាសធាតុអំណោយផល និងល័ក្ខខ័ណ្ឌដាំដុះល្អ) ជាសូចនាករប្រាប់អំពីសក្តានុពល N P និង K ដែលមាននៅក្នុងដីនៅក្នុងរដូវដាំដុះមួយ (រូបភាពទី ៣)។ ប្រើប្រាស់គ្រាប់ពូជដែលមានគុណភាពល្អ និងអនុវត្តតាមការគ្រប់គ្រងដំណាំអោយបានសមស្រប ដែលរួមមានការគ្រប់គ្រងកត្តាចង្រៃ និងទឹក។

- ជ្រើសរើសស្រែ ចំនួន ១០ -២០ ស្រែ របស់កសិករគំរូ សម្រាប់ដែនអនុសាសន៍មួយ ហើយបង្កើតជាកូនស្រែមួយដែលមានទំហំ ២០ ម៉ែត្រ - ៥ ម៉ែត្រ នៅក្នុងស្រែរបស់កសិករនីមួយៗ។ បែងចែក កូនស្រែដែលមិនដាក់សារធាតុចិញ្ចឹមមួយចំនួន ចំនួន ៤ ដែលមានទំហំ ៥ ម៉ែត្រ - ៥ ម៉ែត្រ (ភ្លឺស្រែត្រូវមានទទឹង ២៥ សង់ទីម៉ែត្រ និងមានកំពស់ ២៥ សង់ទីម៉ែត្រ ដើម្បីទប់ស្កាត់ចលនារបស់សារធាតុចិញ្ចឹមពីកូនស្រែមួយទៅកូនស្រែមួយទៀត) :

 0 N ទិន្នផលកំនត់ដោយ N គឺត្រូវបានវាស់វែងនៅក្នុងកូនស្រែដែលមិនដាក់សារធាតុចិញ្ចឹម N ដែលទទួលបានដី P និង K ប៉ុន្តែមិនទទួលបានដី N ទេ។ បង្កើតភ្លឺស្រែ ដើម្បីទប់ស្កាត់ការលាយឡំគ្នានៃជីឆ្លងកាត់កូនស្រែនីមួយៗនៅពេលដែលកសិករប្រើប្រាស់ជីNទៅលើផ្នែកដទៃទៀតរបស់ស្រែនោះ ក្នុងអំឡុងនៃរដូវដាំដុះ។

 0 P ទិន្នផលកំនត់ដោយ P គឺត្រូវបានវាស់វែងនៅក្នុងកូនស្រែខ័ណ្ឌចែកដាច់ពីគ្នា P។ កូនស្រែនេះទទួលបានដី N និង K ប៉ុន្តែមិនទទួលបានដី P ទេ។ ប្រើប្រាស់ដី N និង K ក្នុងបរិមាណច្រើនគ្រប់គ្រាន់ ដើម្បីសម្រេចបាននូវគោលដៅទិន្នផល។

0 K ទិន្នផលកំនត់ដោយ K គឺត្រូវបានវាស់វែងនៅក្នុងកូនស្រែខ័ណ្ឌចែកដាច់ពីគ្នា K។ កូនស្រែនេះទទួលបាន ដី N និង P តែមិនទទួលបានដី K ទេ។ ប្រើប្រាស់ដី N និង P ក្នុងបរិមាណច្រើនគ្រប់គ្រាន់ ដើម្បីសម្រេចបាន នូវគោលដៅទិន្នផល។

NPK ទិន្នផលដែលទទួលបាន គឺត្រូវបានវាស់វែងនៅក្នុងកូនស្រែដែលទទួលបានដី N P និង K។ ប្រើប្រាស់ដី N P និង K ក្នុងបរិមាណច្រើនគ្រប់គ្រាន់ ដើម្បីសម្រេចបាននូវគោលដៅទិន្នផលសម្រាប់ដែនអនុសាសន៍នោះ។

នៅក្នុងកូនស្រែ 0 P, 0 K និង NPK ត្រូវអនុវត្តតាមគំរូសមស្របនៃការបែងចែកការប្រើប្រាស់ដី N ដើម្បីចៀសវាងការដួលដើម។ ផ្តល់ Zn និងពពួកមីក្រូធាតុចិញ្ចឹមដទៃទៀតក្នុងបរិមាណគ្រប់គ្រាន់ ទៅអោយកូនស្រែទាំងអស់ ក្នុងករណីដែលកង្វះសារធាតុចិញ្ចឹមទាំងនេះ បានកើតមានឡើងជាទូទៅ។




រូបភាពទី ៣ ប្លង់នៃបន្សំរបស់កូនស្រែ NPK និងកូនស្រែខ័ណ្ឌចែកដាច់ពីគ្នានៅក្នុងស្រែរបស់កសិករ។ បើអាចធ្វើបាន ត្រូវចៀសវាងខ័ណ្ឌស្រែនៅកន្លែងដែលកសិករបត់ត្រលប់មកវិញ នៅពេលភ្ជួរដី។

- នៅពេលស្រូវទុំ, ត្រូវវាស់វែងទិន្នផលគ្រាប់ ពីផ្ទៃកកណ្តាល ២ ម៉ែត្រ - ២.៥ ម៉ែត្រ នៅក្នុងកូនស្រែដែលមិនដាក់សារធាតុចិញ្ចឹមមួយចំនួននីមួយៗ។ កាត់កួរស្រូវទាំងអស់ ហើយដាក់វានៅលើបន្ទះផ្លាស្ទិច ដើម្បីទប់ស្កាត់នូវការបាត់បង់ទិន្នផល។ ច្បូតយកគ្រាប់ស្រូវទាំងអស់ដោយប្រុងប្រយ័ត្ន ហើយយកគ្រាប់ស្កកចេញ និងពង្រាយគ្រាប់ស្រូវទាំងនោះនៅលើបន្ទះផ្លាស្ទិច។ សំងួតគ្រាប់ស្រូវក្រោមពន្លឺព្រះអាទិត្យអោយបានរយៈពេលពេញមួយថ្ងៃ ដើម្បីទទួលបានអត្រាសំណើមគ្រាប់ប្រហែល ១២-១៦ ភាគរយ។ នៅរដូវភ្លៀង គេត្រូវការរយៈពេល ២-៣ ថ្ងៃ ដើម្បីសំងួតគ្រាប់ស្រូវក្រោមកំដៅព្រះអាទិត្យ។ បង្ហាញពីទិន្នផលគ្រាប់ (grain yield, GY) គិតជាតោនក្នុងមួយហិចតា។

- គណនារកមធ្យមរបស់ទិន្នផលគ្រាប់ដែលប៉ាន់ស្មាន ដែលទទួលបានមកពី ១០-២០ ស្រែរបស់កសិករគំរូទាំងនោះ សម្រាប់ប្រភេទកូនស្រែដែលមិនដាក់សារធាតុចិញ្ចឹមមួយចំនួននីមួយៗ ដើម្បីទទួលបាន
  - ទិន្នផលមធ្យមដែលកំនត់ដោយ N (ទិន្នផលនៅក្នុងប្រភេទកូនស្រែ 0 N)
  - ទិន្នផលមធ្យមដែលកំនត់ដោយ P (ទិន្នផលនៅក្នុងប្រភេទកូនស្រែ 0 P)
  - ទិន្នផលមធ្យមដែលកំនត់ដោយ K (ទិន្នផលនៅក្នុងប្រភេទកូនស្រែ 0 K)
  - ទិន្នផលដែលទទួលបាន (ទិន្នផលក្នុងកូនស្រែ NPK) សម្រាប់ដែនអនុសាសន៍នោះ។

▶ ប្រសិនបើការវាស់ទិន្នផលនៅក្នុងកូនស្រែដែលមិនដាក់សារជាតុចិញ្ចឹមមួយចំនួនទាំងនោះ បានបង្ហាញពីភាពខុសគ្នាខ្លាំងនៃសារជាតុចិញ្ចឹមរបស់ដី នៅតាមទីកន្លែងជាក់លាក់នានានៃដែនអនុសាសន៍របស់អ្នក, ត្រូវគិតពិចារណាក្នុងការបែងចែងដែនអនុសាសន៍នោះ ជាតំបន់ពីរ រឺច្រើន។ ជាទូទៅ ទិន្នផលមធ្យមក្នុងកូនស្រែដែលមិនដាក់សារជាតុចិញ្ចឹមមួយចំនួន គួរតែខុសគ្នាយ៉ាងហោចណាស់ក៏ ១ តោនក្នុងមួយហិចតាដែរ ដើម្បីបែងចែកដែនអនុសាសន៍នោះជា ដែនអនុសាសន៍ចំនួន ២ ដាច់ពីគ្នា។

*កំណាត់សំគាល់ :*

- វាមានភាពចាំបាច់ណាស់ក្នុងការទទួលយកយុទ្ធសាស្ត្រគ្រប់គ្រង N សមស្របសម្រាប់កូនស្រែ 0 P, 0 K និង NPK ពីព្រោះការស្រូបយក P និង K របស់ដំណាំស្រូវ គឺត្រូវបានជះឥទ្ធិពលយ៉ាងខ្លាំង ដោយការគ្រប់គ្រង N ដែលជាសារជាតុចិញ្ចឹមដែលខ្វះខាតខ្លាំងជាងគ។ កម្រិតប្រើប្រាស់ជី N គួរតែមានកម្រិតខ្ពស់គ្រប់គ្រាន់ដើម្បីសម្រេចអោយបានប្រហែល ៧៥-៨០ ភាគរយ នៃសក្តានុពលទិន្នផល ហើយពេលវេលា និងការបែងចែកការប្រើប្រាស់ជី N គួរតែមានលក្ខណៈសមស្របបំផុត (ជំហានទី ៣)។ កុំធ្វើតាមការអនុវត្តរបស់កសិករនាពេលបច្ចុប្បន្នក្នុងការគ្រប់គ្រង N នៅក្នុងកូនស្រែ 0 P, 0 K និង NPK អោយសោះ។
- ដោយអាស្រ័យទៅលើទិន្នផល និងរដូវ, ត្រូវប្រើប្រាស់ផូស្វាតយ៉ាងហោចណាស់ ៣០-៤៥ គីឡូក្រាមក្នុងមួយហិចតា នៅក្នុងកូនស្រែ 0 K និងប៉ូតាស់ យ៉ាងហោចណាស់ ៥០-១០០ គីឡូក្រាមក្នុងមួយហិចតា នៅក្នុងកូនស្រែ 0 P។
- ការប្រើប្រាស់ទិន្នផលគ្រាប់ជាសូចនាករប្រាប់អំពីសក្តានុពលនៃបរិមាណសារជាតុចិញ្ចឹម មានសុពលភាពបានលុះត្រាតែវាត្រូវបានវាស់វែងនៅក្នុងរដូវដែលមានល័ក្ខខ័ណ្ឌអាកាសធាតុអំណោយផល និងមានការគ្រប់គ្រងដំណាំបានសមស្រប។ទិន្នផលគួរតែមិនត្រូវបានកំណត់ដោយកត្តាផ្សេងទៀតដូចជាការផ្គត់ផ្គង់សារជាតុចិញ្ចឹមដទៃទៀត ការផ្គត់ផ្គង់ទឹក និងកត្តាចង្រៃ និងជំងឺ។ កុំប្រើទិន្នន័យទាំងនោះ ប្រសិនបើការខូចខាតទិន្នផលដោយសារការដួលដើម កណ្ដុរ កត្តាចង្រៃ។ល។ មានទំហំធំ។
- បរិមាណសារជាតុចិញ្ចឹមដែលមានស្រាប់នៅក្នុងដី ដែលត្រូវបានវាស់វែងតាមរយៈទិន្នផលគ្រាប់ មានបរិមាណតិចចំពោះស្រូវដាំដោយគ្រាប់ ព្រោះសើមជាងស្រូវសន្ទូង ដោយសារការវាស់វែងដោយទិន្នផលគ្រាប់បែបនេះរងឥទ្ធិពលពីពូជ និងរបៀបដាំដុះ។ ដូចនេះវាមានសារៈសំខាន់ក្នុងការវាស់វែងសារជាតុចិញ្ចឹមដែលមានស្រាប់នៅក្នុងដី ដោយប្រើប្រាស់វិធីសាស្ត្រដាំដុះរបស់កសិករ។
- ប្រសិនបើការអនុវត្តន៍របស់កសិករនាពេលបច្ចុប្បន្ន មានការប្រើប្រាស់ជីសរីរាង្គ ដូចជាជីសរីរាង្គដែលបានមកពីកសិដ្ឋានបន្ថែមទៅលើជីអសរីរាង្គ ត្រូវប្រើប្រាស់ជីសរីរាង្គក្នុងបរិមាណស្មើគ្នាទៅក្នុងកូនស្រែដែលមិនដាក់សារជាតុចិញ្ចឹមមួយចំនួននីមួយៗ។

## *ជំរើស N1: វិធីសាស្ត្រតាមពេលវេលាជាក់ស្តែង*

ក្នុងរដូវកាលដាំដុះ កសិករជាញឹកញាប់តែងតែប្រើប្រាស់ពណ៌ស្លឹក ជាសូចនាករមួយដែលអាចមើលឃើញដោយភ្នែកទៅលើស្ថានភាពអាសូតរបស់ដំណាំស្រូវ និងដើម្បីកំណត់ពីតម្រូវការក្នុងការប្រើប្រាស់ជី N។ តារាងពណ៌ស្លឹក(LCC)គឺជាឧបករណ៍វិភាគដែលមានតម្លៃថោកនិងងាយស្រួលប្រើប្រាស់ដើម្បីពិនិត្យមើលស្ថានភាព

N របស់រុក្ខជាតិនៅក្នុងរដូវដាំដុះនោះ និងជាជំនួយដល់ការសម្រេចចិត្តក្នុងការរៀបចំផែនការបាចជីបំប៉ន N។ បរិមាណជី N ដែលត្រូវបានកំណត់ ត្រូវបានគេប្រើប្រាស់នៅពេលដែលពណ៌របស់ស្លឹកស្រូវបានធ្លាក់ចុះទាបជាងកម្រិតគ្រោះថ្នាក់នៅលើតារាងពណ៌ស្លឹក ដែលបញ្ជាក់ថាមានកង្វះ N នៅក្នុងដំណាំស្រូវ។ វាអាចជួយដល់កសិករក្នុងការកែតម្រូវការប្រើប្រាស់ជី N អោយបានសមស្របទៅនឹងល័ក្ខខ័ណ្ឌអាកាសធាតុជាក់លាក់តាមរដូវកាល (ហៅថា ការគ្រប់គ្រង N តាមពេលវេលាជាក់ស្តែង)។ ការគ្រប់គ្រង N តាមពេលវេលាជាក់ស្តែងបានល្អបានកាត់បន្ថយតម្រូវការជី N, បង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ N និងកាត់បន្ថយភាពមិនធន់ទ្រាំរបស់ដំណាំទៅនឹងកត្តាចង្រៃ និងជំងឺនានា។

## *គោលការណ៍គ្រឹះនៃវិធីសាស្ត្រតាមពេលវេលាជាក់ស្តែង*

តារាងពណ៌ស្លឹកដែលមានលក្ខណៈស្តង់ដា (មើលរូបភាពនៅលើគំរបខាងមុខ) ដែលត្រូវបានអភិវឌ្ឍ និងផ្តល់ដោយវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) តាំងពីឆ្នាំ ២០០៣ មក មានបន្ទះពណ៌បៃតងចំនួន ៤ ដែលមានចាប់ពីពណ៌បៃតងខ្ចី (លេខ ២) រហូតដល់ពណ៌បៃតងចាស់ (លេខ ៥)។ តម្លៃគ្រោះថ្នាក់នៅលើតារាងពណ៌ស្លឹកអាចមានចាប់ពីលេខ ២ រហូតដល់លេខ ៤ អាស្រ័យទៅលើពូជ និងរបៀបដាំដុះដំណាំ ហើយប្រសិនបើស្ថិតទាបជាងតម្លៃគ្រោះថ្នាក់នៃតារាងពណ៌ស្លឹក គួរបាច ជី N។ កត់សំគាល់ថា តម្លៃគ្រោះថ្នាក់នៅលើតារាងពណ៌ស្លឹកដែលមាននៅក្នុងតារាងទី ៤ គួរតែត្រូវបានក្រិតខ្នាតអោយសមស្របទៅតាមល័ក្ខខ័ណ្ឌក្នុងស្រុក។

**តារាងទី ៤ : ឧទាហរណ៍នៃតម្លៃគ្រោះថ្នាក់នៅលើតារាងពណ៌ស្លឹក ដែលអាស្រ័យទៅលើពូជ និងរបៀបដាំដុះដំណាំ**

| ពូជ | របៀបដាំដុះដំណាំ | តម្លៃគ្រោះថ្នាក់នៅលើតារាងពណ៌ស្លឹក |
|---|---|---|
| ស្រូវក្រអូប | - | ២ |
| Semidwarf indica | ព្រោះគ្រាប់ | ៣ |
| Semidwarf indica | ស្ទូង | ៣.៥ |
| អ៊ីប្រ៊ីត | ស្ទូង | ៣.៥ |

## *ការណែនាំសម្រាប់ការប្រើប្រាស់តារាងពណ៌ស្លឹក*

ធ្វើអំណានពណ៌ស្លឹក ចំនួនម្តងជារៀងរាល់ ៧-១០ ថ្ងៃ ដោយចាប់ផ្តើមបន្ទាប់ពីរយៈពេល ១៤ ថ្ងៃបន្ទាប់ពីស្ទូងចំពោះស្រូវសន្ទូង រឺ ២១ ថ្ងៃបន្ទាប់ពីការព្រោះគ្រាប់ ចំពោះស្រូវដែលដាំដោយការព្រោះគ្រាប់សើម។ អំណានចុងក្រោយបំផុត ត្រូវបានធ្វើឡើងនៅពេលដែលឬស្រូវចេញផ្កា (ចេញផ្កាដំបូង)។ ប្រសិនបើកសិករមិនចង់ធ្វើអំណានច្រើនដង, ត្រូវណែនាំអោយប្រើប្រាស់វិធីសាស្ត្រដោះស្រាយតាមពេលវេលាជាក់លាក់ (fixed-time approach) (ជំរើស N2) ដែលក្នុងវិធីសាស្ត្រនេះ អំណានពណ៌ស្លឹកនៅលើតារាងពណ៌ស្លឹក ត្រូវបានធ្វើឡើងតែនៅដំណាក់កាលលូតលាស់សំខាន់ៗរបស់ដំណាំតែប៉ុននោះ ដូចជាដំណាក់កាលបែកគុម្ពខ្លាំង និងដំណាក់-កាលកំណាក់កំណើតកួរ (មើល A-9)។

- ជ្រើសរើសស្លឹកដែលលូតលាស់ពេញរូបរាង ហើយស្ថិតនៅខ្ពស់ជាងគេ (Y leaf) សម្រាប់ការវាស់វែងពណ៌ស្លឹក ពីព្រោះវាជាសូចនាករមួយដ៏ល្អ ដើម្បីបង្ហាញពីស្ថានភាព N របស់ស្រូវ។ វាស់ពណ៌របស់ស្លឹកមួយ ដោយការប្រៀបធៀបពណ៌នៃផ្នែកកណ្ដាលរបស់ស្លឹកជាមួយនឹងពណ៌នៅក្នុងតារាង។ ប្រសិនបើពណ៌ស្លឹកស្ថិតនៅចន្លោះតម្លៃលេខចំនួនពីរ, មធ្យមនៃតម្លៃលេខទាំងពីរនោះ ត្រូវបានយកជាអំណាននៃតារាងពណ៌ស្លឹកនោះ។ ឧទាហរណ៍ ប្រសិនបើពណ៌ស្លឹកស្ថិតនៅចន្លោះតម្លៃលេខ ៣ និង ៤, គេកំណត់ថាជាតម្លៃ ៣.៥។
- ក្នុងពេលវាស់វែង ត្រូវតែអោយស្លឹកដែលកំពុងត្រូវបានវាស់វែងនោះស្ថិតក្រោមម្លប់នៃស្រមោលដងខ្លួនរបស់អ្នកគ្រប់ពេល ពីព្រោះអំណានពណ៌ស្លឹកត្រូវបានជះឥទ្ធិពល ដោយសារទីតាំង និងថាមពលពន្លឺរបស់ព្រះអាទិត្យ។ បើអាចធ្វើទៅបាន, មនុស្សដដែលនោះ គួរតែធ្វើអំណានតារាងពណ៌ស្លឹក នៅពេលវេលាដូចគ្នានៃថ្ងៃនោះ រៀងរាល់ពេលដែលធ្វើការវាស់វែងនោះ។
- ធ្វើអំណាន ចំនួន ១០ ស្លឹកពីគុម្ពនានា ដែលត្រូវបានជ្រើសរើសដោយចៃដន្យក្នុងស្រែមួយ។ ប្រសិនបើស្លឹកចំនួន ៦ រឺច្រើនជាងនេះ បង្ហាញតម្លៃពណ៌ដែលទាបជាងតម្លៃគ្រោះថ្នាក់, ត្រូវប្រើប្រាស់ជី N ភ្លាម។
- កម្រិតណែនាំក្នុងការប្រើប្រាស់ជី N សម្រាប់ពូជស្រូវអាំងឌីកា ដែលមានកំពស់ទាបមធ្យម (semidwarf indica) ត្រូវបានផ្តល់អោយនៅក្នុងតារាងទី ៥។

តារាងទី ៥ : បរិមាណជី N ដែលត្រូវបានស្នើឡើង ដើម្បីប្រើប្រាស់ម្តងៗទៅលើពូជ semidwarf indica នៅពេលពណ៌ស្លឹកធ្លាក់ចុះក្រោមតម្លៃគ្រោះថ្នាក់នៅលើតារាងពណ៌ស្លឹក

| ការកើនឡើងតាមការរំពឹងទុកនៃទិន្នផលនៅក្នុងកូនស្រែ O N (តោន/ហិចតា) | កម្រិតប្រើប្រាស់ក្នុងកំឡុងពេលបន្ទាប់ពី ១៤ ថ្ងៃ បន្ទាប់ពីស្ទូង រឺ ២១ ថ្ងៃ បន្ទាប់ពីព្រោះគ្រាប់ រហូតដល់ដំណាក់កាលកំណាកំណើតកួរ (គីឡូក្រាម/ហិចតា)[a] |
|---|---|
| ១-២ | ២៥ |
| ២-៣ | ៣៥ |
| ៣-៤ | ៤៥ |

*a ប្រើប្រាស់ប្រហែល ២៥ គីឡូក្រាមក្នុងមួយហិចតា បន្ទាប់ពីដំណាក់កាលកំណាកំណើតកួរ រហូតដល់ដំណាក់កាលផ្ការីកដំបូង*

## *គោលការណ៍សម្រាប់កែតម្រូវតារាងពណ៌ស្លឹក*

ការពិសោធន៍សម្រាប់កែតម្រូវតារាងពណ៌ស្លឹក អាចត្រូវធ្វើឡើងនៅកន្លែងស្រាវជ្រាវ រឺនៅលើស្រែរបស់កសិករ។ ជ្រើសរើសពូជក្នុងស្រុកដែលគេនិយមដាំ ចំនួន ៣-៤ ពូជ ហើយធ្វើការប្រៀបធៀបសំដែងកម្ម (performance) របស់ដំណាំស្រូវនីមួយៗ ដោយប្រើប្រាស់តម្លៃគ្រោះថ្នាក់ខុសៗគ្នានៅលើតារាងពណ៌ស្លឹក (ឧទាហរណ៍ ៣, ៣.៥ និង ៤)។ ប្រើប្រាស់ជី N ដោយប្រើប្រាស់តារាងពណ៌ស្លឹក ដូចដែលបានរៀបរាប់ខាងលើ។ ក្រៅពីការប្រើប្រាស់ជី, ក៏ត្រូវកត់ត្រាពីទិន្នផលគ្រាប់ និងសមាសភាពទិន្នផល (កត់ក៏បាន, មិនកត់ក៏បាន), ពិន្ទុសម្រាប់វាយតំលៃពីការលេចឡើងនៃកត្តាចង្រៃ និងជំងឺ, និងទំហំនៃការដួលដើម។

- ជ្រើសរើសប្លង់ពិសោធន៍សម្រាប់ពិសោធន៍ ដែលមានកត្តាច្រើន (factorial design) សម្រាប់ការពិសោធន៍នៅលើស្ថានីយ៍ (on-station experiments) ឧទាហរណ៍ ពូជចំនួន ៣ និងតម្លៃគ្រោះថ្នាក់ចំនួន ៣ នៅលើតារាងពណ៌ស្លឹក ជាបច្ច័យនៅក្នុងប្លុកចាប់ឆ្នោតពេញលេញ (randomized complete block design) ដោយមាន ៤ សារ។

- ប្រើប្រាស់ស្រែកសិករធ្វើជាសារ ប្រសិនបើអ្នកសម្រេចចិត្តធ្វើការពិសោធន៍កែតម្រូវ (calibration trials) នៅលើស្រែរបស់កសិករ។ ជ្រើសរើសស្រែកសិករយ៉ាងតិចចំនួន ៤ ក្នុងមួយពូជ ធ្វើជាសារ ហើយធ្វើការសាកល្បងតម្លៃគ្រោះថ្នាក់នៅលើតារាងពណ៌ស្លឹកចំនួន ២-៣ តម្លៃ នៅក្នុងស្រែនីមួយៗ។

- រួមបញ្ចូលនូវកូនស្រែមួយដែលមិនមានការប្រើប្រាស់ជី ដើម្បីគណនាប្រសិទ្ធភាពក្សេត្រសាស្ត្រ (agronomic efficiency, AE, ការកើនឡើងនៃទិន្នផលគ្រាប់គិតជាគីឡូក្រាមក្នុងមួយខ្នាតជី ដែលត្រូវបានប្រើប្រាស់, មើលចំណុច ១.៣) សម្រាប់បច្ច័យផ្សេងៗគ្នា។

- តម្លៃគ្រោះថ្នាក់នៅលើតារាងពណ៌ស្លឹក អាស្រ័យយ៉ាងខ្លាំងទៅលើពូជ និងរបៀបដាំដុះដំណាំ (តារាងទី ៤) រីឯបរិមាណជីដែលត្រូវប្រើប្រាស់ក្នុងការប្រើប្រាស់ជីបែងចែក (split application) ម្តងៗ គឺមានលក្ខណៈខុសគ្នាទៅតាមរដូវ ហើយអាស្រ័យយ៉ាងខ្លាំងទៅលើការរំពឹងទុកនៃកើនឡើងទិន្នផល ដែលការកើនឡើងនេះត្រូវបានរងឥទ្ធិពលពីអាកាសធាតុ (តារាងទី ៥)។

## *កំណត់សំគាល់ :*

- ដោយសារតែវិធីសាស្ត្រតារាងពណ៌ស្លឹក គឺជាវិធីសាស្ត្រមួយក្នុងការគ្រប់គ្រង N ដែលពឹងផ្អែកទៅលើរុក្ខជាតិ, ការប៉ាន់ប្រមាណទៅលើទិន្នផលប្រហាក់ប្រហែល ដែលកម្រិតដោយ N គឺមានការទាមទារអោយមានការសម្រេចចិត្តទៅលើតំរូវការក្នុងការប្រើប្រាស់ជី N នៅដំណាក់កាលដំបូង មុនសន្ទូងមានអាយុ ១៤ ថ្ងៃ ចំពោះស្រូវសន្ទូង។ ការមិនប្រើប្រាស់ជី N នៅដំណាក់កាលដំបូងនេះ អាចកាត់បន្ថយនូវការបែកគុម្ពរបស់ដំណាំស្រូវនៅក្នុងដីស្រែដែលមានសារជាតុ N ទាប។ ដូចនេះ ត្រូវសម្រេចចិត្តថាតើការប្រើប្រាស់ជីដំបូងនេះ មានភាពចាំបាច់ រឺអត់ ដូចដែលបានបង្ហាញនៅក្នុងជំរើស N2 (មើលចំណុចខាងក្រោម) ហើយប្រើប្រាស់តារាងពណ៌ស្លឹកដើម្បីកែតម្រូវទៅលើការប្រើប្រាស់ជី N ដែលត្រូវបាចបំប៉ននៅពេលបន្ទាប់ ដូចដែលបានរៀបរាប់ក្នុងចំណុចនេះ។

- ការគ្រប់គ្រង N ដោយផ្អែកទៅលើតារាងពណ៌ស្លឹក នឹងមានលក្ខណៈកាន់តែជោគជ័យថែមទៀត នៅពេលដែលគេប្រើប្រាស់វាជាផ្នែកមួយ នៃយុទ្ធសាស្ត្រចម្រុះក្នុងការគ្រប់គ្រងសារជាតុចិញ្ចឹមទៅតាមទីកន្លែងជាក់លាក់។ ដើម្បីទទួលបាននូវការឆ្លើយតបល្អបំផុតទៅនឹងការប្រើប្រាស់ជី N សារជាតុចិញ្ចឹមដទៃទៀត (P, K, S, Zn) មិនត្រូវខ្វះខាតឡើយ។ ប្រើប្រាស់ P និង K ដូចដែលបានបង្ហាញក្នុងជំហានទី ៤ និង ៥ (មើលចំណុចខាងក្រោម), និងពពួកមីក្រូជាតុ (S, Zn) ដោយផ្អែកទៅលើការធ្វើតេស្តដី រឺអនុសាសន៍ក្នុងស្រុក។

- កង្វះសារជាតុ P (ចំណុច ២.២) ធ្វើអោយស្លឹកមានពណ៌ក្រមៅដែលនាំអោយមានអំណានខុសនៅលើតារាងពណ៌ស្លឹក។

- ការក្រិតខ្នាតទៅតាមតំបន់នៅលើតារាងពណ៌ស្លឹក មានគុណប្រយោជន៍សម្រាប់ការគ្រប់គ្រង N ទៅតាមពេលវេលាជាក់ស្តែង។ ឯកសារណែនាំដ៏សាមញ្ញមួយដែលសរសេរជាភាសាតាមតំបន់ គួរតែមានភ្ជាប់ជាមួយនូវតារាងពណ៌ស្លឹក និងពន្យល់កសិករពីរបៀបកំណត់បរិមាណ និងពេលវេលានៃការប្រើប្រាស់ជី N ទៅលើដំណាំស្រូវរបស់ពួកគាត់ទៅតាមរដូវដាក់លាក់ណាមួយ។

## *ជំរើស N2 : វិធីសាស្ត្រតាមពេលវេលាកំណត់* (fixed-time approach)

វិធីសាស្ត្រតាមពេលវេលាកំណត់ផ្តល់ជាអនុសាសន៍មួយសម្រាប់តម្រូវការជី N សរុប (គិតជាគីឡូក្រាមក្នុងមួយហិចតា) និងផែនការសម្រាប់ការបែងចែក និងពេលវេលានៃការប្រើប្រាស់ជី N អោយសមស្របទៅលើដំណាក់កាលលូតលាស់របស់ដំណាំ រដូវកាលដាំដុះ ប្រភេទពូជ និងវិធីសាស្ត្រដាំដុះដំណាំ។

គោលការណ៍គ្រឹះនៃវិធីសាស្ត្រតាមពេលវេលាកំណត់ :

*ប៉ាន់ប្រមាណទៅលើបរិមាណជី N សរុបដែលត្រូវការ ហើយបង្កើតប្រតិទិនសម្រាប់ការប្រើប្រាស់ចំណែកជី N និមួយៗ។ ប្រើប្រាស់តារាងពណ៌ស្លឹកនៅដំណាក់កាលលូតលាស់សំខាន់ៗ ដើម្បីកែតម្រូវកម្រិតប្រើប្រាស់ជី N ដែលត្រូវបានកំណត់ទុកពីពេលមុន។*

តារាងទី ៦ : កម្រិតជី N ដោយផ្អែកទៅលើការឆ្លើយតបរបស់ទិន្នផលដែលទទួលបាន (គោលដៅទិន្នផល - ទិន្នផលនៅក្នុងកូនស្រែ 0 N) និងប្រសិទ្ធភាពក្សេត្រសាស្ត្ររបស់ N តាមការរំពឹងទុក (AEN, ការកើនឡើងនៃទិន្នផលគ្រាប់គិតជាគីឡូក្រាម/គីឡូក្រាមនៃជី N)

| ប្រសិទ្ធភាពក្សេត្រសាស្ត្ររបស់ N (បំរែបំរួលនៃគ្រាប់ស្រូវគិតជាគីឡូក្រាម/គីឡូក្រាមនៃជី N) → | ១៦.៧ | ២០ | ២៥ |
|---|---|---|---|
| ការឆ្លើយតបរបស់ទិន្នផលទៅនឹងការប្រើប្រាស់ជី N (តោន/ហិចតា) ↓ | កម្រិតជី N (គីឡូក្រាម/ហិចតា) | | |
| ១ | ៦០ | ៥០ | ៤០ |
| ២ | ១២០ | ១០០ | ៨០ |
| ៣ | ១៨០ | ១៥០ | ១២០ |
| ៤ | ◄ | ២០០ | ១៦០ |
| ៥ | ◄ | ◄ | ២០០ |

◄ *បញ្ជាក់ពីគោលដៅទិន្នផលដែលមិនអាចកើតមាន*

ប្រើប្រាស់តារាងទី ៦ ដើម្បីគណនាកម្រិតប្រើប្រាស់ជី N សរុប ដោយផ្អែកទៅលើ

- ការឆ្លើយតបនៃទិន្នផលដែលរំពឹងទុក ទៅនឹងការប្រើប្រាស់ជី N ដែលគណនាចេញពីភាពខុសគ្នារវាងគោលដៅទិន្នផល និងទិន្នផលនៅក្នុងកូនស្រែ 0 N (ជំហានទី ១ និង ២) និង
- ប្រសិទ្ធភាពក្សេត្រសាស្ត្ររបស់ជី N ដែលទទួលបាន (AEN, មើលទំព័រទី ៧-៨)។

*ការអនុវត្តជាក់ស្តែង:* ប្រើប្រាស់ជី N ចំនួន ៤០-៦០ គីឡូក្រាមក្នុងមួយហិចតា សម្រាប់ទិន្នផលគ្រាប់រំពឹងទុកក្នុងមួយតោនៗឆ្លើយតប ទៅនឹងការប្រើប្រាស់ជី N។

ប្រើប្រាស់ N ក្នុងបរិមាណតិច ទៅអោយដំណាំក្នុងរដូវវស្សា (ពន្លឺព្រះអាទិត្យតិច, ការឆ្លើយតបរបស់ទិន្នផលមានកម្រិតទាប) និងប្រើប្រាស់ N ក្នុងបរិមាណច្រើន ទៅអោយដំណាំក្នុងរដូវប្រាំង (ពន្លឺព្រះអាទិត្យច្រើន, ការឆ្លើយតបរបស់ទិន្នផលមានកម្រិតខ្ពស់)។

ជ្រើសរើសការឆ្លើយតបរបស់ទិន្នផលរំពឹងទុក ≥ ៤ តោនក្នុងមួយហិចតា លើទិន្នផលនៅក្នុងកូនស្រែ 0 N សម្រាប់តែក្នុងរដូវដែលផ្តល់ទិន្នផលខ្ពស់ រួមជាមួយល័ក្ខខ័ណ្ឌអាកាសធាតុអនុគ្រោះតែប៉ុននោះ។

បទពិសោធន៍នៅអាស៊ីត្រូពិចបង្ហាញថា AEN ស្មើនឹង ២៥ ត្រូវបានគេសម្រេចបានជាញឹកញាប់ តាមរយៈការគ្រប់គ្រងដំណាំបានល្អនៅក្នុងរដូវដែលផ្តល់ទិន្នផលខ្ពស់ ហើយ AEN ស្មើនឹង ១៦.៧ រឺ ២០ ត្រូវបានគេសម្រេចបាន តាមរយៈការគ្រប់គ្រងដំណាំបានល្អនៅក្នុងរដូវដែលផ្តល់ទិន្នផលទាប។ គួកត់សំគាល់ថា ជាទូទៅ AEN តែងតែខ្ពស់ជាងនៅកម្រិត N ទាប ជាជាងនៅកម្រិត N ខ្ពស់។ គោលបំណងនៃការគ្រប់គ្រង N អោយមានប្រសិទ្ធភាពហើយមិនប៉ះពាល់ដល់បរិស្ថាននៅក្នុងតំបន់ត្រូពិច គឺដើម្បីទទួលបានទិន្នផលខ្ពស់ និងមានលក្ខណៈសេដ្ឋកិច្ច តែត្រូវចាំថា AEN ល្អបំផុតគឺការកើនឡើងទិន្នផលគ្រាប់ នៅចន្លោះ ១៦.៧ និង ២៥ គីឡូក្រាមក្នុងមួយគីឡូក្រាមជី N។ នៅក្នុងអាកាសធាតុស៊ុបត្រូពិច ការឆ្លើយតបរបស់ទិន្នផលអាច > ៥ តោនក្នុងមួយហិចតារួមជាមួយ AEN ល្អបំផុត > ២៥ គីឡូក្រាម ទិន្នផលគ្រាប់ក្នុងមួយគីឡូក្រាមជី N ដែលនៅក្នុងករណីនេះកម្រិតជី N ដែលមាននៅក្នុងតារាងទី ៦ និងត្រូវធ្វើការកែតម្រូវ។

- ▸ បែងចែកបរិមាណជីNសរុបនៅក្នុងអនុសាសន៍ ទៅជាការប្រើប្រាស់ជី ចំនួន២-៤ ដង។ បង្កើនចំនួនដងនៃការដាក់ជីថែមទៀត ទៅលើពូជដែលមានអាយុកាលវែង ហើយស្ថិតក្នុងរដូវផ្តល់ទិន្នផលខ្ពស់។ ប្រើប្រាស់ជី N បន្ថែមទៀត នៅពេលដែលតម្រូវការ N របស់ដំណាំមានបរិមាណច្រើន (ឧទាហរណ៍ ចន្លោះពេលចាប់ពីពាក់កណ្តាលនៃដំណាក់កាលបែកគុម្ព រហូតដល់ដំណាក់កាលចេញផ្កា)។ ប្រើប្រាស់ជី N តែមួយដងក្នុងបរិមាណលើស ៤៥ គីឡូក្រាមក្នុងមួយហិចតា តែក្នុងករណីដែលល័ក្ខខ័ណ្ឌអាកាសធាតុអំណោយផលខ្លាំង ហើយការឆ្លើយតបរបស់ដំណាំទៅនឹង N មានទំហំធំតែប៉ុននោះ។

- ▸ ប្រើប្រាស់តារាងទី ៧-៩ ដើម្បីគណនានូវកំរិតជីប្រើម្តងៗ។ យើងតែងតែដឹងពីពេលវេលានៃ

ប៉ុន្តែកាលបរិច្ឆេទពិតប្រាកដក្នុងការប្រើប្រាស់ជីគឺអាស្រ័យទៅលើពូជ (អាយុកាលរបស់ដំណាំ)។ចំពោះដំណាំស្រូវតំបន់ត្រូពិច ដំណាក់កាលកំណកំណើតកួរ មានរយៈពេលប្រហែល ៦០ ថ្ងៃ មុនពេលប្រមូលផល ហើយដំណាក់កាលបែកគុម្ពសកម្ម មានរយៈពេលស្មើរស្មើពាក់កណ្តាលនៃចន្លោះរយៈពេលរវាង ១៤ ថ្ងៃបន្ទាប់ពីស្ទូង រឺ ២១ ថ្ងៃបន្ទាប់ពីព្រោះ និងដំណាក់កាលកំណកំណើតកួរ។

- ▸ ប្រើប្រាស់ការណែនាំខាងក្រោមដើម្បីកំណត់ពីតំរូវការក្នុងការប្រើប្រាស់ជី N នៅដំណាក់កាលដំបូង ទៅអោយដើមស្រូវខ្ចីៗ មុនពេលស្រូវសន្ទូងមាន ១៤ រឺស្រូវពង្រោះមានអាយុ ២១ :
  - ▸▸ មិនត្រូវប្រើប្រាស់ជីដំបូង នៅពេលដែលការឆ្លើយតបរបស់ទិន្នផល ≤ ១ តោនក្នុងមួយហិចតា។ នៅពេលដែលការឆ្លើយតបរបស់ទិន្នផលស្ថិតនៅចន្លោះ ១ ទៅ ៣ តោនក្នុងមួយហិចតា ជាធម្មតាត្រូវប្រើប្រាស់ N ប្រហែល ២០ ទៅ ៣០ គីឡូក្រាមក្នុងមួយហិចតា។ នៅពេលដែលការឆ្លើយតបរបស់ទិន្នផល > ៣ តោនក្នុងមួយហិចតា ត្រូវប្រើប្រាស់ជីN នៅដំណាក់ដំបូងប្រហែល ២៥ ទៅ ៣០ ភាគរយនៃ N សរុប។

- ▸▸ កាត់បន្ថយ រឺបំបាត់ចោលនូវការប្រើប្រាស់ជី N នៅដំណាក់កាលដំបូង នៅពេលដែលមានការប្រើជីកំប៉ុស្ត រឺសារធាតុសរីរាង្គដែលមានគុណភាពខ្ពស់។

- ▸▸ ចៀសវាងការប្រើប្រាស់ជី N នៅដំណាក់កាលដំបូងក្នុងបរិមាណច្រើន (លើសពី ៥០ គីឡូក្រាម N ក្នុងមួយហិចតា) ទៅលើស្រូវសន្ទូង ពីព្រោះការលូតលាស់នៅដំណាក់កាលដំបូងមានភាពយឺត ហើយការស្រូបយក N ក៏តិចតួចផងដែរ ក្នុងអំឡុងរយៈពេល ៣ សប្តាហ៍ដំបូងបន្ទាប់ពីស្ទូង។

- ▸▸ បង្កើនការប្រើប្រាស់ជី N នៅដំណាក់កាលដំបូង សម្រាប់ពូជដែលមានក្តួរធំ ហើយបែកគុម្ពតិច នៅពេលសំណាបចាស់ (មានអាយុច្រើនជាង ២៤ ថ្ងៃ) រឺចំពោះពូជដែលមានអាយុកាលខ្លី ស្រែដែលមានចន្លោះគុម្ពធំ (តិចជាង ២០ គុម្ព ក្នុងមួយម៉ែត្រក្រឡា) ដើម្បីបង្កើនការបែកគុម្ព រឺនៅក្នុងតំបន់ដែលសីតុណ្ហភាពទឹក និងខ្យល់ទាប នៅពេលស្ទូង រឺព្រោះ (ដូចជានៅរយៈកំពស់ខ្ពស់ៗ)។

- ▸▸ ភ្ជួរលុប ជី N ដំបូង ទៅក្នុងដីមុនពេលដាំ រឺប្រើប្រាស់ជី N ដំបូង ក្នុងរយៈពេល ១៤ ថ្ងៃបន្ទាប់ពីស្ទូង រឺ ២១ ថ្ងៃបន្ទាប់ពីព្រោះ។ ប្រើប្រាស់តែ $NH_4$-N ជាប្រភេទជី N សំរាប់ដាក់ដំបូង។ គេមិនចាំបាច់ប្រើប្រាស់តារាងពណ៌ស្លឹកក្នុងការគណនាបរិមាណជី N សំរាប់ប្រើដំបូងនេះទេ។

▸ ប្រើប្រាស់តារាងពណ៌ស្លឹក ដើម្បីវាយតម្លៃទៅលើស្ថានភាព N នៅក្នុងស្លឹក និងតម្រូវការ N របស់ដំណាំបន្ទាប់ពីសន្ទូងមានអាយុ ១៤ ថ្ងៃ រឺអាយុ ២១ ថ្ងៃ ចំពោះស្រូវពង្រោះ។ បង្កើនកម្រិតប្រើប្រាស់ជី N នៅពេលដែលស្លឹកមានពណ៌បៃតងលឿង ហើយបន្ថយកម្រិតប្រើប្រាស់ជី N វិញ នៅពេលដែលស្លឹកមានពណ៌បៃតង។

▸ ប្រើប្រាស់បរិមាណ N នៅដំណាក់កាលក្រោយ (ឧទាហរណ៍ នៅដើមដំណាក់កាលចេញក្តួរ) ដើម្បីពន្យារអាយុកាលរបស់ស្លឹក និងបង្កើនការដាក់គ្រាប់ ប៉ុន្តែប្រើប្រាស់បានតែទៅលើដំណាំស្រូវមានសុខភាពមាំមួនប្រកបទៅដោយសក្តានុពលទិន្នផលល្អតែប៉ុននោះ។ ពូជស្រូវអ៊ីប្រ៊ីត និងពូជដែលមានក្តួរធំ នៅក្នុងរដូវដែលផ្តល់ទិន្នផលខ្ពស់ តែងតែត្រូវការជី N នៅដើមដំណាក់កាលចេញក្តួរ។ ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការដួលដើម និងកត្តាចង្រៃនានា សូមកុំប្រើប្រាស់បរិមាណជី N ច្រើនហួសប្រមាណនៅចន្លោះនៃដំណាក់កាលកំណកំណើតក្តួរ និងដំណាក់កាលចេញផ្កា ពិសេសក្នុងរដូវដែលផ្តល់ទិន្នផលទាប។

▸ ចំពោះតារាងពណ៌ស្លឹករបស់វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) ដែលស្របតាមបទដ្ឋានជាមួយនឹងពូជស្រូវភាគច្រើន ពណ៌ស្លឹកដែលបានរៀបរាប់នៅក្នុងតារាងទី ៧ -៩ ត្រូវគ្នាជាមួយនឹងតម្លៃនៅលើតារាងពណ៌ស្លឹក ដែលមានដូចខាងក្រោម

- ▸▸ ពណ៌បៃតងខ្ចី (Yellowish green) = តម្លៃស្មើនឹង ៣ នៅលើតារាងពណ៌ស្លឹក

- ▸▸ ពណ៌ស្ថិតនៅចន្លោះនៃពណ៌បៃតងនិងពណ៌បៃតងខ្ចី(Intermediate)=តម្លៃ៣.៥នៅលើតារាងពណ៌ស្លឹក (តម្លៃកណ្តាលនៃ ៣ និង ៤) និង

- ▸▸ ពណ៌បៃតង (Green) = តម្លៃ ៤ នៅលើតារាងពណ៌ស្លឹក

- កម្រិតប្រើប្រាស់ជី នៅក្នុងតារាងទី ៧-៩ គឺដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការប្រើប្រាស់ N (ប្រសិទ្ធភាពក្សេត្រសាស្ត្ររបស់ N រឺ AEN) ដែលមានការកើនឡើងទិន្នផលគ្រាប់ប្រហែល ១៦.៧ - ២០ គីឡូក្រាមក្នុងមួយគីឡូក្រាមជី N ដែលត្រូវបានប្រើប្រាស់នៅក្នុងរដូវដែលមានការឆ្លើយតបនូវទិន្នផលរំពឹងទុកចំនួន ១-២ តោនក្នុងមួយហិចតា ទៅនឹងការប្រើប្រាស់ជី N និងការកើនឡើងទិន្នផលគ្រាប់ ២៥ គីឡូក្រាម ក្នុងមួយគីឡូក្រាមជី N ដែលបានប្រើប្រាស់នៅក្នុងរដូវដែលមានការឆ្លើយតបនូវទិន្នផលរំពឹងទុក ៣-៤ តោនក្នុងមួយហិចតាទៅនឹងការប្រើប្រាស់ជី N (មើលតារាងទី ៦)។

- ប្រើប្រាស់តារាងពណ៌ស្លឹក ក្នុងការត្រួតពិនិត្យស្ថានភាព N របស់ដំណាំ ដើម្បីធ្វើអោយបរិមាណនៃការប្រើប្រាស់ជីម្តងៗមានលក្ខណៈសមស្របជាមួយនឹងតម្រូវការរបស់ដំណាំ និងការផ្គត់ផ្គង់ N របស់ដី។ កម្រិតប្រើប្រាស់ជី N សម្រាប់ពណ៌ស្លឹកជាក់លាក់ (តម្លៃនៅលើតារាងពណ៌ស្លឹក) ក្នុងតារាងទី ៧-៩ មានគោលបំណងផ្តល់ជាការសម្របខ្លួនអោយបានសមស្រប ដើម្បីកែតម្រូវស្ថានភាពនៅពេលដែលការឆ្លើយតបរបស់ដំណាំទៅនឹងការប្រើប្រាស់ជីនៅក្នុងរដូវ និងតំបន់មួយ មានលក្ខណៈខុសគ្នាយ៉ាងខ្លាំងជាមួយនឹងការកើនឡើងនៃទិន្នផលតាមការរំពឹងទុក។

- កម្រិត N នៅក្នុងតារាងទី ៧-៩ អាចត្រូវបានកែតម្រូវ និងបន្ថែមបន្ថយ ដើម្បីអោយសមស្របជាមួយពូជស្រូវ និងល័ក្ខខ័ណ្ឌដុះលូតលាស់របស់ដំណាំទៅតាមទីកន្លែងជាក់ស្តែង។

*១. ស្រូវសន្ទូង (ពូជធម្មតា) (មើលតារាងទី ៧)*

មាន ២០-៤០ គុម្ពក្នុងមួយម៉ែត្រក្រឡា, ពូជធម្មតាដែលផ្តល់ទិន្នផលខ្ពស់, មានការលិចទឹកជាប់ជាប្រចាំ រឺការស្រោចស្រពបង្ហាក់។ ស្រូវសន្ទូងមានការលូតលាស់ផ្ទៃស្លឹកយឺត ការបង្កើតសារជាតុស្ងួតយឺត និងការស្រូបយក N យឺត នៅក្នុងដំណាក់កាលលូតលាស់ដំបូង ប៉ុន្តែមានអត្រាលូតលាស់ និងការស្រូបយក N ខ្ពស់ ចាប់ពីពាក់កណ្តាលនៃដំណាក់កាលបែកគុម្ព រហូតដល់ដំណាក់កាលដាក់គ្រាប់។

*២. ស្រូវ ពង្រោះដោយប្រើគ្រាប់សើម (មើលតារាងទី ៧)*

ប្រើប្រាស់គ្រាប់ពូជចំនួន ៨០-១៥០ គីឡូក្រាមក្នុងមួយហិចតា សំរាប់ស្រូវពង្រោះពង្រោះពូជសាមញ្ញដែលផ្តល់ទិន្នផលខ្ពស់មានការលិចទឹកជាប់ជាប្រចាំបន្ទាប់ពីការដុះពន្លករបស់ដំណាំស្រូវ។ស្រូវពង្រោះពង្រោះដោយប្រើគ្រាប់សើម មានការលូតលាស់ផ្ទៃស្លឹកឆាប់រហ័ស ការបង្កើតសារជាតុស្ងួតលឿន និងការស្រូបយក N លឿននៅក្នុងដំណាក់កាលលូតលាស់ដំបូង ប៉ុន្តែអត្រាលូតលាស់ និងការស្រូបយក N យឺត បន្ទាប់ពីដំណាក់កាលកំណាក់ណើតកួរ ជាពិសេសក្នុងដំណាក់កាលដាក់គ្រាប់។ ការងាប់ស្លឹក និងការដួលដើមមានសភាពធ្ងន់ធ្ងរទៅលើដំណាំស្រូវពង្រោះជាជាងទៅលើស្រូវសន្ទូង។ ស្រូវពង្រោះដោយប្រើគ្រាប់សើម មិនត្រូវការ រឺត្រូវការជី N តិចតួចនៅដំណាក់កាលក្រោយមកទៀត។

*៣. ស្រូវសន្ទូង (អ៊ីប្រ៊ីត) (មើលតារាងទី ៨)*

មាន ២០-៣០ គុម្ព ក្នុងមួយម៉ែត្រក្រឡា, ពូជអ៊ីប្រ៊ីតដែលផ្តល់ទិន្នផលខ្ពស់, លិចទឹកជាប់ជាប្រចាំ រឺមានការស្រោចស្រពបន្ថែម។ ស្រូវអ៊ីប្រ៊ីតដែលដាំដោយស្ទូង តែងតែឆ្លើយតបបានល្អទៅនឹងការប្រើប្រាស់ជី N នៅដំណាក់កាលក្រោយក្នុងរដូវដែលផ្តល់ទិន្នផលខ្ពស់។

តារាងទី ៧ : ការបែងចែកការប្រើប្រាស់ជី N ចំពោះស្រូវដែលមានពូជសុទ្ធ **(inbred rice)** ដែលដាំដោយស្ទូង និងដោយព្រោះគ្រាប់សើម ដែលស្រូវនេះមានប្រសិទ្ធភាពខ្ពស់ក្នុងការប្រើប្រាស់ N

| ការកើនឡើងតាមការរំពឹងទុកនៃទិន្នផល នៅក្នុងកូនស្រែ O N ⟶ | | ១ តោន/ហិចតា | ២ តោន/ហិចតា | ៣ តោន/ហិចតា | ៤ តោន/ហិចតា |
|---|---|---|---|---|---|
| ដំណាក់កាលលូតលាស់ | ពណ៌ស្លឹក[a] | កម្រិតជី N ( គីឡូក្រាម/ហិចតា ) | | | |
| មុនពេលដាំរហូតដល់ ១៤ ថ្ងៃ បន្ទាប់ពីស្ទូង រឺ ២១ ថ្ងៃ បន្ទាប់ពីព្រោះគ្រាប់ | | - | ២០ | ៣០ | ៤៥ |
| បែកគុម្ពសកម្ម | បៃតងខ្ចី | ៣៥ | ៤៥ | ៤៥ | ៦០ |
| | ចន្លោះកណ្តាល | ២៥ | ៣៥ | ៣៥ | ៤៥ |
| | បៃតង | - | - | ២៥ | ២៥ |
| កំណកំណើតកួរ | បៃតងខ្ចី | ៣៥ | ៤៥ | ៦០ | ៦០ |
| | ចន្លោះកណ្តាល | ២៥ | ៣៥ | ៤៥ | ៤៥ |
| | បៃតង | - | ២៥ | ២៥ | ៣៥ |

[a] *មើលអត្ថបទនៅទំព័រ A-6 នៅក្នុងឧបសម្ព័ន្ធសម្រាប់តម្លៃឆ្លើយតបនៅលើតារាងពណ៌ស្លឹក*

តារាងទី ៨ : ការបែងចែកការប្រើប្រាស់ជី N ចំពោះស្រូវអ៊ីប្រ៊ីតដែលដាំដោយស្ទូង ដែលមានប្រសិទ្ធភាពខ្ពស់ ក្នុងការប្រើប្រាស់ N

| ការកើនឡើងតាមការរំពឹងទុកនៃទិន្នផល នៅក្នុងកូនស្រែ O N ⟶ | | ១ តោន/ហិចតា | ២ តោន/ហិចតា | ៣ តោន/ហិចតា | ៤ តោន/ហិចតា |
|---|---|---|---|---|---|
| ដំណាក់កាលលូតលាស់ | ពណ៌ស្លឹក[a] | កម្រិតជី N ( គីឡូក្រាម/ហិចតា ) | | | |
| មុនពេលដាំរហូតដល់ ១៤ ថ្ងៃ បន្ទាប់ពីស្ទូង | | - | ២០ | ៣០ | ៤៥ |
| បែកគុម្ពសកម្ម | បៃតងខ្ចី | ៣៥ | ៤៥ | ៤៥ | ៦០ |
| | ចន្លោះកណ្តាល | ២៥ | ៣៥ | ៣៥ | ៤៥ |
| | បៃតង | - | - | ២៥ | ២៥ |
| កំណកំណើតកួរ | បៃតងខ្ចី | ៣៥ | ៤៥ | ៦០ | ៦០ |
| | ចន្លោះកណ្តាល | ២៥ | ៣៥ | ៤៥ | ៤៥ |
| | បៃតង | - | ២៥ | ២៥ | ៣៥ |
| ចេញកួរដំបូង | បៃតងខ្ចី | - | - | ២០ | ២០ |

[a] *មើលអត្ថបទនៅទំព័រ A-6 នៅក្នុងឧបសម្ព័ន្ធសម្រាប់តម្លៃឆ្លើយតបនៅលើតារាងពណ៌ស្លឹក*

*៤. ស្រូវ សន្ទូង(ប្រភេទមានកួរធំៗ) (មើលតារាងទី ៩)*

ស្រូវផ្តល់ទិន្នផលខ្ពស់ដែលមានកួរធំ (ប្រភេទស្រូវដែលមានកួរធ្ងន់) មានការបែកគុម្ពតិច និងមានភាពធន់ទ្រាំបានល្អទៅនឹងការដួលដើម។ ពួកស្រូវប្រភេទនេះ រួមបញ្ចូលទាំងដំណាំស្រូវប្រភេទថ្មី និងស្រូវអ៊ីប្រ៊ីតមួយចំនួន ដូចជាស្រូវអ៊ីប្រ៊ីត "super" របស់ចិន។

តារាងទី ៩ : ការបែងចែកការប្រើប្រាស់ជី N ចំពោះប្រភេទស្រូវដែលមានកួរធំ (ប្រភេទកួរធ្ងន់)

| ការកើនឡើងនៃទិន្នផលតាមការរំពឹងទុក នៅក្នុងកួនស្រែ ON → | | ១ តោន/ហិចតា | ២ តោន/ហិចតា | ៣ តោន/ហិចតា | ៤ តោន/ហិចតា |
|---|---|---|---|---|---|
| ដំណាក់កាលលូតលាស់ | ពណ៌ស្លឹក[a] | កម្រិតជី N (គីឡូក្រាម/ហិចតា) | | | |
| មុនពេលដាំរហូតដល់ ១៤ ថ្ងៃ បន្ទាប់ពីស្ទូង | | ២៥ | ៣០ | ៤០ | ៥០ |
| បែកគុម្ពសកម្ម | បៃតងខ្ចី | - | ៣៥ | ៤៥ | ៤៥ |
| | ចន្លោះកណ្តាល | - | ២៥ | ៣៥ | ៣៥ |
| | បៃតង | - | - | ២៥ | ២៥ |
| កំណកំណើតកួរ | បៃតងខ្ចី | ៤៥ | ៤៥ | ៤៥ | ៦០ |
| | ចន្លោះកណ្តាល | ៣៥ | ៣៥ | ៣៥ | ៤៥ |
| | បៃតង | ២៥ | ២៥ | ២៥ | ៣៥ |
| ចេញកួរដំបូង | | - | - | ២៥[b] | ២៥[b] |

[a] *មើលអត្ថបទនៅទំព័រ A-6 នៅក្នុងឧបសម្ព័ន្ធសម្រាប់តម្លៃឆ្លើយតបនៅលើតារាងពណ៌ស្លឹក*

[b] *ប្រើប្រាស់ N ដោយមិនគិតពីអំណានពណ៌ស្លឹក*

### *កំណត់សំគាល់ :*

✍ មិនត្រូវបាចជីបំប៉ន N នៅមុនពេលមានភ្លៀងធ្លាក់ខ្លាំង។

## *ជំហានទី ៤ : ការគណនាកម្រិតជីផូស្វាត ($P_2O_5$)*

គោលបំណងសំខាន់នៃការគ្រប់គ្រង P គឺដើម្បីទប់ស្កាត់កង្វះ P ជាជាងដើម្បីព្យាបាលរោគសញ្ញានៃកង្វះ P។ ប្រសិនបើជាតិ P នៅក្នុងដីមានកម្រិតទាបនោះ ធ្វើអោយកសិករមិនអាចសម្រេចបាននូវទិន្នផលគោលដៅ ចំពោះការគ្រប់គ្រងកសិករត្រូវតែផ្តោតការយកចិត្តទុកដាក់ទៅលើការបង្កើន និងរក្សាកម្រិត P សេរីរបស់ដីអោយមានបរិមាណគ្រប់គ្រាន់ ដើម្បីធានាថា ការផ្គត់ផ្គង់ P មិនបានកំណត់ទៅលើការលូតលាស់របស់ដំណាំ និង ប្រសិទ្ធភាពនៃការប្រើប្រាស់ N ឡើយ។

P មិនបាត់បង់ចេញពីប្រព័ន្ធនេះដោយងាយៗឡើយ ប៉ុន្តែប្រភពនានារបស់វា ដូចជា ទឹកស្រោចស្រព និងចំបើង ជាទូទៅមានបរិមាណតិចតួច។ ការប្រើប្រាស់ជី P ធ្វើអោយមានឥទ្ធិពលយូរអង្វែង ហើយការរក្សា P របស់ដីទាមទារអោយមានយុទ្ធសាស្ត្រសំរាប់រយៈពេលយូរអង្វែងហើយសមស្របជាមួយល័ក្ខខ័ណ្ឌជាក់លាក់របស់ទីកន្លែងដាំដុះ ដោយត្រូវគិតគូរពិចារណាទៅលើប្រភព P ពីគ្រប់មជ្ឈដ្ឋានទាំងអស់។

ការគ្រប់គ្រង P ប្រកបនិរន្តរភាព ទាមទារអោយមានការបំពេញឡើងវិញនូវបរិមាណ P បំរុងទុករបស់ដី ពិសេសសំរាប់ប្រព័ន្ធដែលដាំដុះដំណាំស្រូវ ២ ដង រឺ ៣ ដង ហើយផ្តល់ទិន្នផលខ្ពស់ សូម្បីតែក្នុងករណីដែលមិនមានការឆ្លើយតបទិន្នផលដោយផ្ទាល់ទៅនឹងការប្រើប្រាស់ជី P គិតគូរក៏ដោយ។

*ការអនុវត្តន៍ជាក់ស្តែង* : នៅកន្លែងដែលជីមានបរិមាណPតិចតួច, ត្រូវប្រើប្រាស់ជីផូស្វាត ($P_2O_5$) ចំនួន ២០ គីឡូក្រាមក្នុងមួយហិចតា សម្រាប់ការកើនឡើងមួយតោនៗនៃទិន្នផលគ្រាប់ដែលចង់បាន (ភាពខុសគ្នារវាងគោលដៅទិន្នផល និងទិន្នផលនៅក្នុងកូនស្រែ 0 P)។

ការរក្សាកម្រិតជី P (maintenance fertilizer P rates) ដែលមាននៅក្នុងតារាងទី ១០ ត្រូវបានរៀបចំឡើងដើម្បីបំពេញឡើងវិញនូវបរិមាណ P ដែលត្រូវបានស្រូបយកតាមរយៈគ្រាប់ និងចំបើង ដោយសន្មតថាការផ្តល់ត្រលប់មកវិញ តាមរយៈកាកសំណល់ដំណាំមានបរិមាណពីតិចទៅមធ្យម។ ស្រាវជ្រាវរកកម្រិតប្រើប្រាស់ជីផូស្វាត ដោយផ្អែកលើ

- គោលដៅទិន្នផល (ជំហានទី ១) និង
- ការប៉ាន់ប្រមាណទៅលើការផ្គត់ផ្គង់ P របស់ដី ដែលត្រូវបានវាស់វែងជាទិន្នផល នៅក្នុងកូនស្រែ 0 P (ជំហានទី ២)។

តាមលក្ខណៈទ្រឹស្តី ការប្រើប្រាស់ជី P មិនមានភាពចាំបាច់ឡើយ ប្រសិនបើគេមិនសង្ឃឹមថាការឆ្លើយតបរបស់ទិន្នផល មិនបានស្មើនឹងគោលដៅទិន្នផលដែលត្រូវបានជ្រើសរើស (មានន័យថា បើគោលដៅទិន្នផល = ទិន្នផលនៅក្នុងកូនស្រែដែលមិនដាក់សារធាតុចិញ្ចឹមមួយចំនួន)។ យុទ្ធសាស្ត្រប្រើប្រាស់ជី P ស្មើសូន្យនេះ បណ្តាលអោយមានការបាត់បង់នូវបរិមាណ P បំរុងទុករបស់ដី ហើយអាចប៉ះពាល់ដល់ទិន្នផលក្នុងរយៈពេលពីមធ្យមទៅរយៈពេលវែង ពិសេសក្នុងករណីដែលមិនមានការប្រើប្រាស់សារធាតុចិញ្ចឹមពីប្រភពដទៃទៀត ដូចជាចំបើង រឺជីសរីរាង្គ។

តារាងទី ១០ : កម្រិតជី $P_2O_5$ សម្រាប់ការថែរក្សា ដោយយោងទៅលើគោលដៅទិន្នផល និងទិន្នផលកម្រិតដោយ P នៅក្នុងកូនស្រែ 0 P

| គោលដៅទិន្នផល (តោន/ហិចតា) → | ៤ | ៥ | ៦ | ៧ | ៨ |
|---|---|---|---|---|---|
| ទិន្នផលនៅក្នុងកូនស្រែ 0 P (តោន/ហិចតា) ↓ | កម្រិតជី $P_2O_5$ (គីឡូក្រាម/ហិចតា) | | | | |
| ៣ | ២០ | ៤០ | ៦០ | ◄ | ◄ |
| ៤ | ១៥ | ២៥ | ៤០ | ៦០ | ◄ |
| ៥ | 0 | ២០ | ៣០ | ៤០ | ៦០ |
| ៦ | 0 | 0 | ២៥ | ៣៥ | ៤៥ |
| ៧ | 0 | 0 | 0 | ៣០ | ៤០ |
| ៨ | 0 | 0 | 0 | 0 | ៣៥ |

◄ *បញ្ជាក់ពីគោលដៅទិន្នផលដែលមិនអាចកើតមាន*